TKI0754

# សម្ភាសន៍ជាមួយ នង គូ ភេទស្រី អាយុ៦២ឆ្នាំ

## មុខងារៈ ប្រធានកងចល័ត

## សព្វថ្ងៃរស់នៅភូមិប្រាសាទ ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ

## ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ផេង ពង្សរ៉ាស៊ី

០១:១៩:៤២

៣៥ទំព័រ

រ៉ាស៊ី ៖ ខ្ញុំឈ្មោះរ៉ាស៊ី ឈ្មោះពេញរបស់ខ្ញុំ ផេង ពង្សរ៉ាស៊ី ហើយគ្នាខ្ញុំនេះឈ្មោះ សេងគា ។ ខ្ញុំពីរនាក់នឹងធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខាងទស្សនាវដ្ដីស្វែងរកការពិតនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានេះ មានគោលបំណងធំៗ២ៈ ទី១ដើម្បីរកយុត្តិធម៌ ហើយទី២ដើម្បីការចងចាំ ។ ការចងចាំនឹង គឺថាការផ្ដល់ពត៌មានពីបងប្អូនយើង ប្រជាជនយើងដែលនៅជុំវិញទូទាំងប្រទេសតាមភូមិឃុំនានា ហើយខាងពួកខ្ញុំយកមកសរសេរជាសាច់រឿង ជាប្រវត្តិរបស់គាត់ម្នាក់ៗ ដើម្បីឲ្យក្មេងៗជំនាន់ក្រោយឲ្យបានរៀនឲ្យបានមើលទៅវាដឹងពីប្រវត្តិពីទុក្ខលំបាកឬពីការងារដែលមីង ឬក៏អ្នកផ្សេងៗទៀតធ្លាប់ធ្វើកាលពីជំនាន់ប៉ុលពត ។

គូ ៖ ចា៎ស!

រ៉ាស៊ី ៖ រកយុត្តិធម៌ គឺខាងខ្ញុំនេះមិនរកយុត្តិធម៌ មិនមានលទ្ធភាពរកយុត្តិធម៌ទេ ប៉ុន្តែខាងខ្ញុំអាចផ្ដល់ជាឯកសារដែលមាន ហើយក៏ដូចជាផ្ដល់បទសម្ភាសន៍ផ្សេងៗ ទៅឲ្យខាងតុលាការដើម្បីពិនិត្យមើល ឬមួយគេស្រាវជ្រាវដំណើរទាក់ទងផ្សេងៗ ទៅនឹងមេដឹកនាំខ្មែរក្រហម ។ អ្នកនាំពាក្យរបស់តុលាការនេះ គាត់បានប្រាប់ហើយថាតុលាការនេះ កាត់ទោសតែមេដឹកនាំធំៗទេ ។ ហើយថ្មីៗនេះ ឌុច ប្រធានគុកទួលស្លែងហៅកាំងហ្គេកអ៊ាវនេះ គាត់ត្រូវតុលាការកាត់ទោសគាត់ហើយៗ នៅថ្ងៃទី២៦ខែ៧យើងនេះ ជិតដល់ហើយ គេនឹងចេញសាលក្រមសម្រេចទោសគាត់ថា តើគាត់ត្រូវជាប់គុកប៉ុន្មានឆ្នាំអីចឹង ។ ហ្នឹងគាត់ជាមនុស្សម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតរបស់របបខ្មែរក្រហម ។ ចំណែកសៀវភៅដែលខ្ញុំជូនមីងនេះ សៀវភៅក្រហមធំនេះ ដាក់ថាសំណុំរឿងលេខ០០២ គឺជាមេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យ ។ អីចឹងនៅក្នុងតុលាការនេះ គេបែងចែកជា២ៈ ១អ្នកទទួកខុសត្រូវខ្ពស់បំផុត គឺឌុចនឹង ហើយ នឹងទី២មេដឹកនាំខ្ពស់បំផុតរបស់របបខ្មែរក្រហមមាន៤នាក់ មាននួន

ជា, អៀង សារី, អៀង ធីរិទ្ធ, ហើយនឹងខៀវ សំផន។ ហើយចឹង ថ្ងៃនេះខ្ញុំមកជួបមីងនេះ គឺចង់ឲ្យមីងជួយជម្រាបពី រឿងរ៉ាវពិតរបស់មីងនៅជំនាន់ប៉ុលពត។ តើមីងធ្វើអីខ្លះ ក្រោយមកគេជម្លៀសទៅណា ឬក៏និយាយទៅរឿងរ៉ាវរបស់មីងផ្ទាល់តែម្តង? តាំងពីមីងនៅក្មេងរហូតមកដល់ពេលដែលមីងចូល មកបម្រើការនៅក្នុងរបបខ្មែរក្រហមនឹង។

គូ ៖ ត្រឹមគេឲ្យធ្វើការនឹង ហ្នឹងចូលទៅ គេហៅទៅនៅស្រុកលើគេមកប្រមូលនារីទៅនៅស្រុកលើ។

វ៉ាស៊ី ៖ ខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអី?

គូ ៖ ខ្ញុំឈ្មោះ គូ។

វ៉ាស៊ី ៖ គូ នាមត្រកូល?

គូ ៖ នង។

វ៉ាស៊ី ៖ នង គូអីចឹងមីង?

គូ ៖ ចា៎ស!

វ៉ាស៊ី ៖ បច្ចុប្បន្នមីងអាយុប៉ុន្មាន?

គូ ៖ អាយុ៦២។

វ៉ាស៊ី ៖ ភូមិនេះគេហៅភូមិអី?

គូ ៖ ភូមិប្រាសាទ។

វ៉ាស៊ី ៖ ឃុំកំពែងនោះ?

គូ ៖ ចា៎ស!

វ៉ាស៊ី ៖ ស្រុកកំណើតមីងនៅណាដែរ?

គូ ៖ ស្រុកកំណើតខ្ញុំនៅនឹង ខាងកើត កាលពីតូចនៅភូមិតាម៉េង។

វ៉ាស៊ី ៖ នៅនឹង?

គូ ៖ ចា៎ស!

វ៉ាស៊ី ៖ មីងមានបងប្អូនប៉ុន្មាននាក់?

គូ ៖ បងប្អូន៤នាក់។

វ៉ាស៊ី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

គូ ៖ ស្រី២ ប្រុស២ ប្រុស១ស្លាប់កាលប៉ុលពត ស្លាប់អាយុ១៧ឆ្នាំ វាស្លាប់គ្រាប់ឡោង គេឡោងមក។

វ៉ាស៊ី ៖ ស្លាប់ដោយសារត្រូវគ្រាប់ឡោង?

គូ ៖ គ្រាប់ផ្លោង ។

រ៉ាស៊ី ៖ ឆ្នាំណា ស្លាប់ឆ្នាំណា?

គូ ៖ ចា៎ស! ដឹងឆ្នាំណា ប្អូនខ្ញុំអាយុ១៧កាលស្លាប់ គេឲ្យទៅត្រៀមសំបុកមាន់ស្លាប់ ។

រ៉ាស៊ី ៖ សំបុកមាន់នៅណា?

គូ ៖ ទល់ដែន ។

រ៉ាស៊ី ៖ ទល់ដែន?

គូ ៖ សោមតាអុល ។

រ៉ាស៊ី ៖ គាត់ជាទាហានដែរ?

គូ ៖ ជាទាហាន គេរើសឲ្យធ្វើទាហាន ។

រ៉ាស៊ី ៖ ទាហានខាងណា?

គូ ៖ ប៉ុលពត ។

រ៉ាស៊ី ៖ ទាហានខាងប៉ុលពត?

គូ ៖ ចា៎ស! ចុះកាលនឹងយើងមានទាហានខាងណា មានតែប៉ុលពតកាលនឹងពេកវើជាមួយយួន ។

រ៉ាស៊ី ៖ ហើយឪពុកម្ដាយមីងឈ្មោះអីខ្លះ?

គូ ៖ ឪឈ្មោះ នង សួន ។

រ៉ាស៊ី ៖ នង សួន?

គូ ៖ ចា៎ស!

រ៉ាស៊ី ៖ ម្ដាយ?

គូ ៖ សែ កាន ។

រ៉ាស៊ី ៖ គាត់នៅរស់ទាំង២នាក់?

គូ ៖ ឪស្លាប់ហើយ ។

រ៉ាស៊ី ៖ គាត់ស្លាប់ដោយសារអី?

គូ ៖ ស្លាប់គាត់ឈឺតាំងពីប៉ុលពតមក ។

រ៉ាស៊ី ៖ គាត់ឈឺអីគេ?

គូ ៖ គាត់ឈឺធ្លាក់ឈាម ។

រ៉ាស៊ី ៖ គ្រាំ?

គូ ៖ ចា៎ស! គេឲ្យវែកដី កោះដើងដីវីនឹង ។

វ៉ាស៊ី ៖ មីងមានបានរៀនអីទេ កាលនៅពីតូច?

គូ ៖ ខ្ញុំរៀនៗបានតិចនឹង រៀនបានថ្នាក់ ។

វ៉ាស៊ី ៖ រៀនថ្នាក់ទីប៉ុន្មាន?

គូ ៖ រៀនថ្នាក់ទី១១នឹង ១១កាលនឹងប្រហែលយើងទី៤-៥អីនឹង ។

វ៉ាស៊ី ៖ កាលនឹងមីងរៀននៅសាលាណា?

គូ ៖ វត្តកំពែង ។

វ៉ាស៊ី ៖ វត្តកំពែងត្រង់ណាវិញ?

គូ ៖ នោះអាដូវទៅពីនឹងចូលវត្តបន្តិច ។

វ៉ាស៊ី ៖ ចូលទៅខាងនឹង?

គូ ៖ ចា៎ស!

វ៉ាស៊ី ៖ សាលាគេដាក់វត្តកំពែង ឬសាលាអីផ្សេង?

គូ ៖ ចា៎ស! បឋមសិក្សាវត្តកំពែង ។

វ៉ាស៊ី ៖ កាលមីងចូលរៀនៗអាយុប៉ុន្មាន?

គូ ៖ ខ្ញុំអាយុ១០ឆ្នាំជាងហើយ ចូលរៀន ចូលតាំងពីអាយុ១០ឆ្នាំ ហើយរៀនបានតិច មិត្តៗនឹង មិត្តគេប្រមូលរត់ទៅលើ ។

វ៉ាស៊ី ៖ ខ្ទង់ឆ្នាំណាមីង ពេលដែលមីងឈប់រៀននៅថ្នាក់ទី១១នឹង?

គូ ៖ កាលរដ្ឋប្រហារនឹងឈប់រៀន ។

វ៉ាស៊ី ៖ អីចឹងពេលរដ្ឋប្រហារនឹងឈប់ សាលាបិទទាំងអស់គ្នា?

គូ ៖ បិទទាំងអស់គ្នា ។

វ៉ាស៊ី ៖ ហើយមីងចេះអានចេះអីទេកាលនឹង?

គូ ៖ ចេះអានមើលតិចៗ ឥឡូវមើលលែងបាន មើលមិនឃើញ ។ ឥឡូវនៅ៣នាក់ ស្រី២ ។

វ៉ាស៊ី ៖ ដល់ពេលឈប់រៀន មីងទៅធ្វើអី?

គូ ៖ ឈប់រៀនមានធ្វើអីនៅផ្ទះរត់តែកាប៉ាល់ហោះ រត់តែគ្រាប់អីចឹងទៅ មើលគោមើលអី ។

វ៉ាស៊ី ៖ ពេលរដ្ឋប្រហារហើយភ្លាម ឬក៏មានមុន ឬក៏ក្រោយ?

គូ ៖ ដល់យូរបន្តិចបាន ។

វ៉ាស៊ី ៖ ដល់យូរប្រហែលជាប៉ុន្មានឆ្នាំ?

គូ ៖ កាលកាប៉ាល់ហោះទម្លាក់ដឹងប៉ុន្មានឆ្នាំ ។

វ៉ាស៊ី ៖ មីងឈប់រៀនបានប៉ុន្មានបានមាន?

គូ ៖ ឈប់បាន២ឆ្នាំហើយ បាន ។

វ៉ាស៊ី ៖ ២ឆ្នាំក្រោយមក បានមានកាប៉ាល់ហោះទម្លាក់?

គូ ៖ ចា៎ស!

វ៉ាស៊ី ៖ កាប៉ាល់ហោះនឹង កាប៉ាល់ហោះខាងណា?

គូ ៖ ប្រហែលជាកាប៉ាល់ហោះយួន អាមេរិច ឡានហោះកាលនឹង មានតែឡានហោះអាមេរិច ឡានហោះទម្លាក់គ្រាប់បែក ។

វ៉ាស៊ី ៖ ទម្លាក់ត្រង់ណាខ្លះទៅ?

គូ ៖ ទម្លាក់ហានទាថ្នល់បំបែកនឹង ទម្លាក់ហានទាខាងកើតវត្តកំពែងនឹង ម៉ុំនឹងអាក្រោះមកឡានហោះ ទម្លាក់បាក់អស់ផ្ទះសម្បែង ម៉ុំនឹង ដើមឈើដើមអី ។

វ៉ាស៊ី ៖ នៅនេះរត់ទាំងអស់គ្នា?

គូ ៖ រត់ទាំងអស់គ្នា ។ ហើយដូចថារថក្រោះមកអីចឹង គេយកអីវ៉ាន់ចាប់ជ្រូក ចាប់មាន់ ចាប់ទា យើង ។ ហើយយើងមិត(រត់) ដល់ក្មេងជំទង់ៗដូចខ្ញុំមិត(រត់)ពួនអីចឹងមិនឲ្យជួបរថក្រោះទេ ហើយនៅភូមិនេះ ឈ្មោះរៀមៗអាក្រោថគេចាប់រំលោភស្លាប់ ។

វ៉ាស៊ី ៖ ចុះពេលនឹងនៅក្នុងភូមិរបស់មីងនេះ ហើយនឹងភូមិហាន់ទានឹងនៅក្នុងតំបន់រំដោះហើយអីចឹង?

គូ ៖ មិនទាន់រំដោះទេកាលនឹង ប៉ុនមក ។

វ៉ាស៊ី ៖ ប៉ុន្តែខ្មែរក្រហមកាន់កាប់ហើយ?

គូ ៖ មកខ្មែរក្រហមវាមានមកហើយ ខ្មែរលាយយួនហើយ ។ ហើយដល់ពេលមានខ្មែរលាយយួន លាយគ្នាអីចឹងឡានហោះមកឃើញ គេទម្លាក់គ្រាប់អីចឹង បាញ់អីចឹងទៅ ។

វ៉ាស៊ី ៖ មានញឹកញាប់ទេ ទម្លាក់?

គូ ៖ កាលនឹងទម្លាក់ញឹក ។

វ៉ាស៊ី ៖ ទម្លាក់នៅហាន់ទាននេះមួយ ទម្លាក់នៅត្រង់ណាទៀត?

គូ ៖ ទម្លាក់នៅហាន់ទានឹងហើយនឹងភូមិយើងអីចឹង ប្លោងមក យើងធ្វើត្រង់សេក្រោមផ្ទះ អាណា ប្លោងមកចំស្លាប់អីចឹងទៅ ។

វ៉ាស៊ី ៖ ប្លោងមិនមែនទម្លាក់ពីលើកាប៉ាល់ហោះ បាញ់ប្លោងមក?

គូ ៖ ទម្លាក់បាញ់ពេលយប់អីចឹងឡានហោះច្រើនបាញ់ៗយប់ក៏មាន ថ្ងៃក៏មានដែរ ។ ដល់ពេលថ្ងៃណានេះ គ្រាប់ប្លោងមកពីយួនអីចឹង ប្លោងមកគ្រាប់វាដាក់ត្រង់ណា វាប្លោងជ្រុំមកភូមិយើងអីចឹង ។

វ៉ាស៊ី ៖ មានបាញ់ពីយួនទៀត?

គូ ៖ មកប្លោងមក អ្នកផ្ទះខ្ញុំមានទូ មានក្ដារធ្នឿអីចឹងវាដឹកយកទៅ កន្ទេលវ៉ាន់យើងធ្វើបានយកជ្រូកមាន់ វាយកវាចាប់កាប់ស៊ីនៅនឹង វាដឹកយកទៅ ។

វ៉ាស៊ី ៖ ដឹងថាពួកនឹងយួនម៉ង?

គូ ៖ យួនអីចឹង គ្រាន់មើលមុខ ដល់ពេលមកនិយាយសុទ្ធតែយួន ។

វ៉ាស៊ី ៖ និយាយសុទ្ធយួន?

គូ ៖ ចា៎ស! គេថាគេនៅស្ពឺស្វាយទង ស្រុកកំណើតគេស្វាយទងក៏មកសុទ្ធតែយួន ដល់ក្មេងស្រីៗគ្មានអ្នកណានៅផ្ទះបានទេ ដល់មិត្ត(រត់)ពួន ទៅព្រៃទៅអីចឹង ។

វ៉ាស៊ី ៖ មានចាប់រំលោភ?

គូ ៖ ចា៎ស! ចាប់រំលោភ ឥឡូវនឹងអីនឹងស្លាប់ហើយស្រករខ្ញុំដែរ ប៉ុនបងខ្ញុំរៀមនឹង ហ្នឹងគេរំលោភខានលិចវត្ត.... ។

វ៉ាស៊ី ៖ ឈ្មោះអីដែរ?

គូ ៖ ឈ្មោះរៀម ។

វ៉ាស៊ី ៖ រៀម?

គូ ៖ ចា៎ស! ស្លាប់ហើយ ស្លាប់តាំងយើងចុះមកពីលើ កាលនឹងមិនទាន់ស្លាប់ ប៉ុនគាត់ឈឺរ៉ែរ៉ៃដល់ស្លាប់ ។

វ៉ាស៊ី ៖ អ្នកដែលរំលោភនឹងគឺវៀតណាមនឹង?

គូ ៖ វៀតណាម ។

វ៉ាស៊ី ៖ អីពួកអីគេហៅពួកវៀតកុង វៀតមិញម៉េច ខ្ញុំមិនសូវយល់ដែរ?

គូ ៖ វៀតកុងនឹងឃើញមកជាមួយខ្មែរក្រហម មានខ្មែរមានវៀតកុង ហើយប៉ុនរថក្រោះនឹងមកក៏យួនដែរ សុទ្ធតែយួនមក ។

វ៉ាស៊ី ៖ អីចឹងយួនមាន២ប្រភេទ?

គូ ៖ យួន២ប្រភេទ អាម៉ាប្រភេទនៅជាមួយខ្មែរក្រហម ម៉ាប្រភេទ ។ ហើយដល់ម៉ែមីលុននឹងឡានហោះបាញ់ស្លាប់ ម៉ែមីលុនស្លាប់កាលចំបក់នឹង ។

វ៉ាស៊ី ៖ លន់ ណាចេះ?

គូ ៖ នៅភូមិនឹងដែរ កាលឡានហោះបាញ់ស្លាប់ នោះនៅកន្លែងដើមចំបក់ វាច្រើនបាញ់យប់ ។

វ៉ាស៊ី ៖ អូ! បាញ់ទាំងយប់?

គូ ៖ ចា៎ស!

វ៉ាស៊ី ៖ ហើយប្រហែលជាឆ្នាំណាបានគេឈប់បាញ់ ពួកឡានហោះឈប់មកបាញ់?

គូ ៖ ដល់ពេលគេរំដោះបានអីចឹង រំដោះនៅតែបាញ់អីចឹង ដល់ពេលយើងរំដោះរដ្ឋប្រហារនឹង យើងរំដោះបាន បានឈប់មានមកបាញ់ ។

វ៉ាស៊ី ៖ រំដោះ៧៥នេះ ខែមេសា៧៥?

គូ ៖ ចា៎ស! បានឈប់បាញ់ ហើយបើកាលនេះគ្មានទេ នៅផ្ទះនឹងនៅមិត(រត់)រាល់ថ្ងៃអីចឹង ឡានហោះទម្លាក់នៅតែមិត(រត់)រាល់ថ្ងៃឡានហោះទម្លាក់នៅតែមិត(រត់) ទ័ពមកអីចឹង គេដាក់ពីកន្ទុំរុយអីចឹង មិត(រត់)ពួនព្រៃអីចឹង ខោអាវមានតិចតួចយកទៅលាក់នៅក្នុងព្រៃទៅ ក្មេងស្រីៗស្រករខ្ញុំនៅតែព្រៃ មកម៉ែឪយកបាយឲ្យហូបទៅ ។

វ៉ាស៊ី ៖ នឹងខ្ទង់ឆ្នាំណា?

គូ ៖ ឆ្នាំ៧០ប៉ុន្មាន ។

វ៉ាស៊ី ៖ អត់ទាន់បែកភ្នំពេញឆ្នាំ៧៥ មុន៧៥?

គូ ៖ ចា៎!មុនបែកភ្នំពេញ មកពួននៅនឹងព្រៃ តែព្រលឹមឡើងចេញទៅ យើងបរទេះទៅ ។

វ៉ាស៊ី ៖ កាលនឹងប្រធានភូមិប្រធានឃុំគេគិតម៉េចទៅ?

គូ ៖ កាលនឹងមិត(រត់)ដូចគ្នា គ្មានអ្នកណានៅ ។

វ៉ាស៊ី ៖ ប្រធានភូមិឈ្មោះអីគេ?

គូ ៖ ប្រធានភូមិកាលជំនាន់នឹងឪខ្ញុំធ្វើប្រធានភូមិ ។

វ៉ាស៊ី ៖ គាត់ធ្វើប្រធានភូមិពីឆ្នាំណា គាត់ធ្វើបានប៉ុន្មានឆ្នាំ?

គូ ៖ គាត់ធ្វើតាំងពីជំនាន់នឹង ធ្វើតាំងពីជំនាន់សម្តេចសីហនុមកឪខ្ញុំ ឆ្នក់ពិសេសអីគេនឹង សម្តេចសីហនុឲ្យប្រគល់កាំភ្លើងឲ្យឆ្នក់ពិសេស ហើយគាត់ធ្វើប្រធានភូមិ ពីដើមគេហៅមេភូមិ ។

វ៉ាស៊ី ៖ ឆ្នក់ពិសេសនឹងគេធ្វើម៉េច?

គូ ៖ ឆ្នក់ពិសេសនឹង ឡាន សម្តេចចែកកាំភ្លើងដើមៗ ។

វ៉ាស៊ី ៖ អានឹងក្រោយរដ្ឋប្រហារហើយ ឬមុនរដ្ឋប្រហារ?

គូ ៖ មុនៗរដ្ឋប្រហារ ។

រ៉ាស៊ី ៖ មុនរដ្ឋប្រហារ?

គូ ៖ ចាស! មុន ។

រ៉ាស៊ី ៖ ដល់ក្រោយរដ្ឋប្រហារហើយ គាត់នៅធ្វើប្រធានភូមិដដែល?

គូ ៖ ធ្វើរដ្ឋប្រហារហើយនឹង ។

រ៉ាស៊ី ៖ មេឃុំឈ្មោះអី?

គូ ៖ ឈ្មោះ តានប់ ឪអឹំហៀនពល់ថ្ងៃ ។

រ៉ាស៊ី ៖ នប់គាត់នៅរស់ទេ?

គូ ៖ ស្លាប់ហើយ ។

រ៉ាស៊ី ៖ កាលនឹងនៅឃុំកំពែងដដែល?

គូ ៖ ចាស! ឃុំកំពែង ។

រ៉ាស៊ី ៖ អីចឹងក្រោយរដ្ឋប្រហារគាត់ធ្វើប្រធានភូមិដដែល ឪពុករបស់មីង?

គូ ៖ ដល់ក្រោយរដ្ឋប្រហារនឹង គាត់មិត(រត់) ។

រ៉ាស៊ី ៖ មិតទៅណា?

គូ ៖ គ្មានអ្នកណានៅធ្វើអីទេ ដល់នឹង ។

រ៉ាស៊ី ៖ អត់មានអីច្បាស់លាស់?

គូ ៖ អឺ!លែងមានអ្នកធ្វើអី ។

រ៉ាស៊ី ៖ ចុះពេលក្រោយមកទៀត ពេលណាចូលធ្វើច្បាស់លាស់?

គូ ៖ គាត់គ្មានធ្វើអី គាត់ឈប់កាលពេលប្រមូលពួកឆ្នក់ពិសេស ប្រមូលឲ្យទៅចូលខ្មែរក្រហម ពួកខ្មែរក្រហមគេប្រមូល ។

រ៉ាស៊ី ៖ គេប្រមូលអ្នកឆ្នក់ពិសេសនឹង?

គូ ៖ ចាស! ដល់ប្រមូលទៅគាត់ចេះរត់ទៅលើជាមួយគេអីចឹង ។

រ៉ាស៊ី ៖ អ្នកណាគេអ្នកមកប្រមូលពួកគាត់?

គូ ៖ ពួកខ្មែរក្រហម ។

រ៉ាស៊ី ៖ ហ្នឹងក្រោយរដ្ឋប្រហារថ្មីៗ ឬក៏យូរក្រោយមកបានប្រមូល?

គូ ៖ យូរដែរ យូរប្រហែលម៉ាឆ្នាំ ។

រ៉ាស៊ី ៖ ហើយកាលនោះគ្នាគាត់មានប៉ុន្មាននាក់ទៅ?

គូ ៖ មិនដឹងប៉ុន្មានដងៗ ប៉ុនខ្ញុំដឹងថាឪខ្ញុំគេហៅទៅកោះអណ្ដែតនឹង ។

វ៉ាស៊ី ៈ និយាយពីខាងក្រោយ៧៩វិញ ក្រោយរំដោះភ្នំពេញឆ្នាំ៧៩ កាលនឹងមីងនៅនឹងដែល ឬក៏មីងទៅណា?

គូ ៈ ខ្ញុំមុនដំបូងគេឲ្យនៅកំពែងនឹង ដល់ពេលនេះ គេផ្លាស់ប្តូរប្រជាជនគេឲ្យនៅសោម ផ្លាស់ប្តូរគ្នាឲ្យទៅនៅកោះអណ្តែតខ្លះ នៅសោមខ្លះ ខ្ញុំគេឲ្យទៅនៅសោម ។

វ៉ាស៊ី ៈ សោមនឹង ជាភូមិ ឬក៏ជា?

គូ ៈ ឃុំសោមទៅនៅ គេផ្លាស់ទៅនៅនឹង ។

វ៉ាស៊ី ៈ ទៅម្នាក់ឯង?

គូ ៈ ចា៎ស! ទៅម៉ែខ្ញុំ ។

វ៉ាស៊ី ៈ ម៉ាភូមិទៅទាំងអស់គ្នា?

គូ ៈ ចា៎ស!

វ៉ាស៊ី ៈ ចុះគេយកភូមិនឹងដាក់អីវិញ?

គូ ៈ ភូមិនឹងគ្មានឃើញមនុស្សនៅផង កន្លែងនឹង ។

វ៉ាស៊ី ៈ សោមនឹងនៅស្រុកគិរីវង់ដែរ?

គូ ៈ ស្រុកគិរីវង់ដែរ ទៅទល់ដែនយួន ។

វ៉ាស៊ី ៈ ម៉េចបានគេឲ្យទៅនៅនឹង?

គូ ៈ គេថាតែក! បើគ្រួសារមានកូនធ្វើទាហានស្លាប់ ធ្វើទ័ពនឹង អីចឹងគេរើសឲ្យទៅនៅនឹង ។

វ៉ាស៊ី ៈ ហើយចុះអ្នកដែលអត់មានកូនស្លាប់?

គូ ៈ អ្នកអត់កូនស្លាប់ ឲ្យតែកូនធ្វើទ័ពនឹង គេយកទៅនៅនឹងដែរ ធ្វើទ័ពប៉ុលពតនឹង ។

វ៉ាស៊ី ៈ អីចឹងកន្លែងជាតំបន់អីវិញ?

គូ ៈ នឹងតំបន់នៅទល់ដែននឹង ខ្មែរក្រហមនៅនឹង ។

វ៉ាស៊ី ៈ ហើយកាលនឹងទៅគ្រួសារទៅជុំគ្នាទាំងអស់ទេ មិនទាន់បែកទេ?

គូ ៈ ចា៎ស!

វ៉ាស៊ី ៈ ទាំងឪពុកមីង ទាំងម្តាយទាំងបងប្អូនទៅទាំងអស់?

គូ ៈ ចា៎ស!

វ៉ាស៊ី ៈ ហើយកាលនឹងអ្នកភូមិនេះទៅទាំងអស់ ហើយមានគ្នាប៉ុន្មាននាក់?

គូ ៈ មិនដឹងប៉ុន្មាននាក់ផង ។

វ៉ាស៊ី ៈ ហើយកាលនឹងអ្នកភូមិនេះទៅទាំងអស់ ហើយមានគ្នាប៉ុន្មាននាក់?

គូ ៖ មិនដឹងប៉ុន្មាននាក់ផង ចេះតែទៅនៅតាម ។

រ៉ាស៊ី ៖ អ្នកណាគេអ្នកមកប្រាប់ឲ្យមីងជម្លៀសទៅនៅសោម?

គូ ៖ អានឹងប្រធានភូមិ ឃុំគេនឹង ។

រ៉ាស៊ី ៖ ឈ្មោះអីទៅ?

គូ ៖ តាញ៉ៅបនឹង ។

រ៉ាស៊ី ៖ គាត់ឡើងពីអន្លង់ ញ៉ៅបនឹង?

គូ ៖ តាញ៉ៅបនឹងមកពីស្រុក១០៥ ។

រ៉ាស៊ី ៖ គាត់មកគ្រប់គ្រងនៅនេះឆ្នាំណា?

គូ ៖ មិនដឹងឆ្នាំណា ។

រ៉ាស៊ី ៖ គ្រាន់បែក៧៥ ឃើញគាត់?

គូ ៖ ចាស! គេវ៉ៃបែកភ្នំពេញ គេរំដោះបាននឹង គេមកនៅនឹងម៉ង ។

រ៉ាស៊ី ៖ តាញ៉ៅបនឹង គាត់ប្រាប់ឲ្យទៅទាំងអស់គ្នាទៅ?

គូ ៖ ចាស!

រ៉ាស៊ី ៖ ចុះគាត់ទៅទេ ញ៉ៅបនឹង?

គូ ៖ អត់ទេ នៅនឹងឃុំគេមានមួយទៀត ឈ្មោះអីទេស្លាប់ហើយ នីម ។

រ៉ាស៊ី ៖ នីម?

គូ ៖ ចាស! ឃុំសោមនឹង ។ ហើយនឹងគេផ្លាស់ប្រជាជនទៅហើយណា ។

រ៉ាស៊ី ៖ មីងទៅនៅនឹងប៉ុន្មានឆ្នាំ ប៉ុន្មានខែបានត្រឡប់មកនៅនេះវិញ?

គូ ៖ អឺ!ទៅនៅបានប្រហែល២-៣ខែ ឃើងមិត(រត់)ទៅលើនឹងទៀត គេវ៉ៃពីក្រោមមកមិត(រត់)ទៅលើ គេវ៉ៃពីក្រោមមកមិត(រត់)ទៅលើ ។

រ៉ាស៊ី ៖ ខាងណាវ៉ៃ?

គូ ៖ ខាងយើងនឹង ខាងសម្តេចហ៊ុន សែន ។

រ៉ាស៊ី ៖ អឺ! វ៉ៃបាន២-៣ខែ?

គូ ៖ នៅ ខ្ញុំតែនេះនៅនេះទៅបានប្រហែល៥-៦ខែ នៅក៏នៅតែខ្លាចនៅវ៉ៃគ្នា ។

រ៉ាស៊ី ៖ ចុះមីងទៅនៅនឹងអត់បានម៉ាឆ្នាំទេ?

គូ ៖ អត់បានម៉ាឆ្នាំ ។

រ៉ាស៊ី ៖ អីចឹងប្រហែលមីងទៅឆ្នាំ៧៨ ៧០អី ។ ចុះពី៧៥ ដល់៧៨ មីងនៅណា នៅនឹង?

គូ ៈ ចា៎ស! នៅនឹង ។

វ៉ាស៊ី ៈ នៅទាំងអស់គ្នា ឬក៏?

គូ ៈ នៅទាំងអស់គ្នា តែប្អូនខ្ញុំមួយទៅធ្វើទ័ព ស្លាប់បែកគ្នា ។

វ៉ាស៊ី ៈ អីចឹងពី៧៥ ដល់៧៨ ភូមិនេះអ្នកណាគេអ្នកគ្រប់គ្រង?

គូ ៈ ប្រធានភូមិដឹងណា ។

វ៉ាស៊ី ៈ ហើយប្រធានឃុំឈ្មោះអីគេ ញៀប?

គូ ៈ ឈ្មោះ ញៀប ។

វ៉ាស៊ី ៈ ឈ្មោះ ញៀប ប៉ុន្តែប្រធានភូមិ?

គូ ៈ ប្រធានភូមិកាលនឹងមិនដឹងណា ។

វ៉ាស៊ី ៈ ញៀបនឹងគាត់នៅទេ?

គូ ៈ ស្លាប់ហើយ កាលប៉ុលពត ដល់នេះគេយកគាត់ទៅសម្លាប់ ថាគាត់មានស្រីគេចាប់ពីនឹងទៅ គាត់ស្រឡាញ់ស្រីពេទ្យនៅឃុំជាមួយគ្នា គេចាប់ទៅ ។

វ៉ាស៊ី ៈ ស្រីពេទ្យ?

គូ ៈ ចា៎ស!

វ៉ាស៊ី ៈ ចុះនៅនេះមានពេទ្យដែរ?

គូ ៈ ពេទ្យកាលប៉ុលពតនឹង ស្រឡាញ់ជាមួយពេទ្យភាព ។

វ៉ាស៊ី ៈ ឥឡូវភាពនឹងនៅនឹង?

គូ ៈ មិនដឹងទៅណាបាត់ផង គេមកពី១០៥ ។

វ៉ាស៊ី ៈ អ្នកណាអ្នកមកចាប់តាញៀបនឹងទៅ?

គូ ៈ កន្លែងស្រុកគេ ឡាន ។

វ៉ាស៊ី ៈ មីងស្គាល់ឈ្មោះ?

គូ ៈ មិនស្គាល់គេទេ ។

វ៉ាស៊ី ៈ ម៉េចបានគេដឹងថាញៀបនឹង ខូចសីលធម៌ជាមួយ?

គូ ៈ ប្រហែលគេ ចុះគេអ្នកធ្វើគេដឹង ។

វ៉ាស៊ី ៈ មីងកាលនឹងគេឲ្យធ្វើអី?

គូ ៈ ខ្ញុំនៅកងចល័ត ។

វ៉ាស៊ី ៈ មីងជាអី នៅក្នុងកងចល័តមាននាទីជាអី?

គូ ៖ ប្រធានក្រុមចល័ត ។

វ៉ាស៊ី ៖ ប្រធានក្រុមកងចល័ត មីងធ្វើពីឆ្នាំណាដល់ឆ្នាំណា?

គូ ៖ ខ្ញុំមិនប្រធានទេ ខ្ញុំសមាជិកគេ ដូចថាគេមានគេធំជាងខ្ញុំ២ ខ្ញុំក្រោមគេអីចឹង ។

វ៉ាស៊ី ៖ មីងចូលកងចល័តពីឆ្នាំណាមក ពី៧៥?

គូ ៖ ចូលមុនៗវល់តែឈឺ ដល់ពេលខ្ញុំជានឹង ចូលបានម៉ាឆ្នាំយើងមិត(រត់) ចូលទៅនៅជាមួយម៉ែឪទៅនៅកងចល័ត ។ កាលមុនក៏នៅកងចល័តដែរ ប៉ុនវល់តែនៅដេកពេទ្យគិរីអីចឹងទៅ ។

វ៉ាស៊ី ៖ អាច៧៦មីងចូល?

គូ ៖ អឺ!

វ៉ាស៊ី ៖ មីងជាប្រធានកងចល័ត?

គូ ៖ ខ្ញុំសមាជិក មិនមែនប្រធានទេ ។

វ៉ាស៊ី ៖ អ្នកណាគេប្រធាន?

គូ ៖ ប្រធាននឹងភី ។

វ៉ាស៊ី ៖ ឥឡូវគាត់នៅណា?

គូ ៖ ភីនឹង ស្រុកកំណើតគេនៅសំរោង ដឹងគេទៅណាមិនដឹងដែរ ។

វ៉ាស៊ី ៖ ភី បងប្អូនគាត់ឈ្មោះផលដែរនឹង?

គូ ៖ ចា៎ស! ហ្នឹងគេរើស ពីជំនាន់នឹងគេរើស២ដំណាក់ អ្នកមានអ្នកក្រ ខ្ញុំនឹងឋានៈម៉ែឪខ្ញុំមធ្យមគេមិនឲ្យ គេមិនឲ្យធ្វើប្រធានទេ ព្រោះខ្ញុំមានខ្សែរយៈខាងធ្វើខាងសម្តេចសីហនុច្រើន បងប្អូនធ្វើខាងនឹងច្រើន គេមិនយកឲ្យធ្វើប្រធានទេ ។ ប្រធាននឹងដល់គេអ្នកក្រ ហើយគេខ្សែរយៈល្អបានគេយក ។

វ៉ាស៊ី ៖ ចុះផលនឹងធ្វើអីទៅ នៅជាមួយគ្នានឹងដែរ?

គូ ៖ ផលនឹងគេ តែនេះគេនៅភូមិកំពែងជាមួយគាញ៉ែបនឹង ។

វ៉ាស៊ី ៖ ផលជាឃុំ?

គូ ៖ គេរដ្ឋបាល ជំនាន់នឹងគេហៅរដ្ឋបាលឃុំ ។ តែប្រធានកងចល័តគេធំលើភីនឹងទៀត ប្រធានកងចល័តស្រុកគេនឹង ជ្រន ។

វ៉ាស៊ី ៖ ជ្រន?

គូ ៖ ជ្រននឹង ស្រុកកំណើតគេនៅកោះអណ្តែត ហើយក៏១០៥ៗនៅខាងស្រុក១០៥ ខ្ញុំមិនច្បាស់ដែរ ។

វ៉ាស៊ី ៖ ភី ហើយ ផលនេះ ការពិត គាត់នៅរស់ទាំង២នាក់?

គូ ៖ គាត់នៅ ។

វ៉ាស៊ី ៖ ហើយភីនេះ ជាប្រធានរបស់មីង?

គូ ៖ ចាស!

វ៉ាស៊ី ៖ គាត់យ៉ាងម៉េចដែរ អត្តចរិតគាត់?

គូ ៖ អត្តចរិតមិនអីប៉ុន្មានទេ គ្រាន់ថាគេប្រធានអីចឹងកាចបន្តិច ។

វ៉ាស៊ី ៖ មានដែលធ្វើបាបមីងទេ?

គូ ៖ ធ្វើបាប គេរាយការណ៍ពីយើង ថាយើងមិនចេះ យើងរវល់តែឈឺ ធ្វើការអីមិនកើត គេស្តីគេដាក់ឲ្យខ្ញុំទៅនៅដដាំបន្លែ ខ្ញុំធ្វើការអីមិនកើតទេ ។

វ៉ាស៊ី ៖ ហើយនៅក្នុងកងចល័តនឹងមានគ្នាប៉ុន្មាននាក់?

គូ ៖ មិនដឹងម៉ាស្រុកគិរីវង់ មិនដឹងប៉ុន្មាន ខ្ញុំមិនមែនប្រធានគេមិនដឹងទាំងអស់មានគ្នាប៉ុន្មាន បើការនេះនៅភូមិអីចឹង ដល់គេប្រមូលទៅនៅកងទាំងអស់គ្នា ចល័តស្រុក ។

វ៉ាស៊ី ៖ មីងម៉េចថាអ្នកដែលធំជាងភីនឹង ឈ្មោះជ្រន?

គូ ៖ អឺ! ជ្រននឹងប្រធានធំជាងគេ ប៉ុនមិនដឹងខ្ញុំក្រោមគេ ។

វ៉ាស៊ី ៖ បើកងចល័ត មានកងចល័តឋានៈណាខ្លះ កងចល័តឃុំ កងចល័ស្រុក កងចល័តតំបន់?

គូ ៖ មុនដំបូងឃុំ គេប្រមូលនៅឃុំកំពែងម៉ាឃុំ ដល់ហើយគេប្រមូលទៅស្រុកមូលគ្នាទាំងអស់ម៉ាស្រុកសុទ្ធតែក្មេងស្រីៗ ។

វ៉ាស៊ី ៖ មូលគ្នាទាំងអស់?

គូ ៖ ចាស!ទៅម៉ាស្រុកមូលគ្នាទាំងអស់ម៉ាស្រុក ។

វ៉ាស៊ី ៖ នៅមូលគ្នាទាំងអស់?

គូ ៖ ចាស! សុទ្ធតែក្មេងស្រីៗ ។

វ៉ាស៊ី ៖ ហើយភីនឹងគាត់គ្រប់គ្រងប៉ុន្មាននាក់ ឬក៏គ្រប់គ្រងទាំងអស់ម៉ាស្រុក?

គូ ៖ គេទាំងអស់ម៉ាស្រុក ។

វ៉ាស៊ី ៖ ម៉ាស្រុកដែរ?

គូ ៖ ចាស!

វ៉ាស៊ី ៖ ចុះជ្រន?

គូ ៖ ជ្រននឹងគេប្រធានលើនឹងទៀត ។

រ៉ាស៊ី ៖ ហើយចុះអ្នកដែលនៅលើជ្រនីងទៀត?

គូ ៖ លើជ្រនីងទៀតធំ មានតែបងខឿននឹង ។

រ៉ាស៊ី ៖ ខឿន?

គូ ៖ ស្គាល់ត្រឹមបងខឿន មិនដឹងថាខឿននឹងមកពី១០៥ ។

រ៉ាស៊ី ៖ ខឿននឹងស្រីប្រុស?

គូ ៖ ស្រី ។

រ៉ាស៊ី ៖ គាត់មកពី១០៥ គាត់ធ្វើអី?

គូ ៖ គាត់ទទួលខុសត្រូវនារីនៅច្រើននឹងទៀត ដល់ទៅមុខទៀតមិនដឹងណាទៀតទេ ខ្ញុំមិនដឹង ។

រ៉ាស៊ី ៖ ទទួលខុសត្រូវលើនារីទាំងអស់នៅក្នុងស្រុកគីរីវង់?

គូ ៖ ស្រុកគីរីវង់ ចាស! ។

រ៉ាស៊ី ៖ មីងដែលឃើញគាត់ទេ?

គូ ៖ ដែលឃើញគាត់មកពេលធ្វើមេទិញ គេមក ដូចថាគេហៅនារីស្រុកប្រជុំ គេមកប្រជុំ ។

រ៉ាស៊ី ៖ មីងដែលបាននិយាយជាមួយគាត់ទេ?

គូ ៖ មិនដែលមានការអីត្រូវនិយាយផង ខ្ញុំដឹងថាដាំបន្លែ បើមិនដាំបន្លែ ជីកប្រឡាយ ក្រុមខ្ញុំ ។

រ៉ាស៊ី ៖ ប្រជុំនឹង ប្រជុំនៅណា មីងបានឃើញគាត់?

គូ ៖ ប្រជុំគេប្រជុំដោយភូមិណាគេត្រូវ ឧទាហរណ៍ថាស្រុកគីរីវង់គេដាក់វត្តមួយ ប្រជុំមួយកន្លែង ។

រ៉ាស៊ី ៖ ប្រជុំនឹងគេនិយាយពីអីខ្លះ?

គូ ៖ គេប្រជុំនិយាយឲ្យយើងកសាងខ្លួន ជីកប្រឡាយខំធ្វើការ ដែលយើងធ្វើការដូចថាយើងជីកប្រឡាយយើងធ្វើបានមាំ គេឲ្យយើងធ្វើឲ្យបានច្រើន ទាំងយប់ទាំងថ្ងៃដកសំណាបម្នាក់ម៉ាប្អូន ២ប្អូនម៉ាថ្ងៃ ម៉ាព្រឹក កំណត់ឲ្យយើងដក អាណាដកបានឈប់ ។

រ៉ាស៊ី ៖ ផែនការគេ?

គូ ៖ ចាស! គេដាក់ផែនការឲ្យអីចឹង ។

រ៉ាស៊ី ៖ ហើយនៅក្នុងកងចល័តទាំងមូលនឹងមានប្រធាន?

គូ ៖ ចាស!

រ៉ាស៊ី ៖ ហើយមានអនុប្រធាន?

គូ ៖ ចាស! អ៊ំខឿនប្រធានធំជាងគេ បន្ទាប់មកជ្រនីង ហើយភីនឹង ៣នាក់ ។

រ៉ាស៊ី ៖ បន្ទាប់មកមានសមាជិក មានមីងនឹង?

គូ ៖ សមាជិកដូចពួកខ្ញុំឃុំកំពែង គេរើសម៉ាឃុំ២-៣នាក់ ឲ្យធ្វើប្រធានក្រុម ខ្ញុំក្រុម១ ។

វ៉ាស៊ី ៖ អីចឹងមីងប្រធានក្រុមនៅកងចល័តនឹង?

គូ ៖ ចា៎ស!

វ៉ាស៊ី ៖ ម៉ាក្រុមមីងមានគ្នាប៉ុន្មាននាក់ទៅ?

គូ ៖ ម៉ាក្រុមខ្ញុំ២៦នាក់ ។

វ៉ាស៊ី ៖ សុទ្ធតែស្រីៗទាំងអស់?

គូ ៖ សុទ្ធតែស្រីទាំងអស់ ក្មេងស្រីៗអាយុ១៧-១៨-២០ ។

វ៉ាស៊ី ៖ ពេលទៅប្រជុំនឹង គេហៅតែពួកមីងទៅប្រជុំ យើងជាប្រធានក្រុម?

គូ ៖ ចា៎ស! គេហៅ ។

វ៉ាស៊ី ៖ ក្រោយមក បានមីងយកបញ្ហានឹងយកមកដាក់បន្ត?

គូ ៖ មក គេប្រជុំប្រាប់យើងអីចឹងហើយ ថាយើងដាស់តឿនសមាជិកក្នុងក្រុមយើងឲ្យខំធ្វើការ ខ្ទាហរណ៍ដូចយើងជីប្រឡាយ គេឲ្យយើងខំធ្វើ គេដាក់កំណត់ឲ្យប៉ុន្មានម៉ែត្រយើងក្នុងម៉ាថ្ងៃនឹង ក្រុមខ្ញុំធ្វើបានខ្ញុំឈប់ទៅ ។ ហើយដកសំណាបខ្ទាហរណ៍ថាគេឲ្យដក ថាម៉ាថ្ងៃនឹង២បួនឬ៣បួន ក្រុមខ្ញុំក្នុងម្នាក់២-៣បួនដកបានស្នានណា ឈប់ស្នាននឹង ។

វ៉ាស៊ី ៖ ខស្សាហ៍ឡើងទៅប្រជុំទេ ម៉ាខែៗមីងប្រជុំប៉ុន្មានដង?

គូ ៖ ខ្ញុំមិនដែលឡើងទៅប្រជុំណាទេ ប្រជុំតែប្រធានគេ គេមកប្រជុំតាមឃុំ ។

វ៉ាស៊ី ៖ បាទ! ប្រធានគេមកប្រជុំតាមឃុំនឹង មីងធ្លាប់ចូលប៉ុន្មានដង ទៅតាមឃុំ ក្នុងម៉ាខែ ឬក៏?

គូ ៖ ម៉ាខែប្រជុំម្តង ។

វ៉ាស៊ី ៖ ប្រជុំម្តង?

គូ ៖ ចា៎ស!

វ៉ាស៊ី ៖ ចុះប្រុសៗទៅណាអស់ទៅ នៅតែស្រីៗ?

គូ ៖ ប្រុសៗ គេក្រុមយុវជនគេ មានប្រធានយុវជនគេនៅក្រុមគេផ្នែកយុវជន យើងនារីនៅខាងនារី ។

វ៉ាស៊ី ៖ ការងារដែលមីងគ្រប់គ្រងក្រុមរបស់មីងនឹង អត់នៅជាមួយកងចល័តផ្សេងទៀតទេ ដឹកនាំធ្វើម៉ាក្រុម?

គូ ៖ នៅម៉ាក្រុមយើង ដូចថាឥឡូវម៉ាស្រុកនឹងមានប៉ុន្មាន មាន១០ក្រុមអីចឹង គេហៅខ្ញុំអីចឹងមួយពូមួយ បួននេះមួយអីចឹងទៅ ។

រ៉ាស៊ី ៖ មេៗក្រុម?

គូ ៖ ថាមេៗក្រុមទៅប្រជុំ ។

រ៉ាស៊ី ៖ ទៅទទួលបញ្ជា?

គូ ៖ ចា៎ស! ទទួលបញ្ជាអីចឹង គេដាក់មក ឥឡូវក្រុមខ្ញុំឲ្យផ្នែកដាំបន្លែ ឲ្យដាំបន្លែឲ្យបានក្នុងម៉ាថ្ងៃៗ ឲ្យ យើងបេះបានបន្លែឲ្យគេបានបន្លែយកហូបគ្រប់ បើថាមិនគ្រប់ទេ ពេលយើងប្រជុំជីវភាព គេថា យើងមិនយកចិត្តទុកដាក់ គេតិះទៀលយើងស្តីយើងល្មមយើងយំ ។ បាយអង្ករហូបក៏គេ បន្ថយយើង គេឲ្យមិនគ្រប់ ដល់ពេលយើងអីចឹង ពេលយើងដាំមិនបានគ្រប់ ។ បើយើងជីក ប្រឡាយ មិនគ្រប់ក៏គេបន្ថយបាយយើង ។

រ៉ាស៊ី ៖ ទាំងអស់មានប៉ុន្មានក្រុមនៅក្នុងកងចល័តនឹង?

គូ ៖ មិនដឹងប៉ុន្មានក្រុមផង ។

រ៉ាស៊ី ៖ តាមដែលមីងដឹង មានប៉ុន្មាន?

គូ ៖ ភ្លេចហើយប្អូន យូរពេកហើយ ដឹងប៉ុន្មានក្រុម ។

រ៉ាស៊ី ៖ ប៉ុនមីងគិតថាមានច្រើន គ្រាន់មីងគិតប្រហាក់ប្រហែលប៉ុន្មាន?

គូ ៖ ប្រហែល ម៉ាស្រុកនឹងប្រហែល២០០នាក់ ។

រ៉ាស៊ី ៖ មើលចែក២០០ចែក២៦ វា៥ក្រុមអីដែរ?

គូ ៖ ចា៎ស!

រ៉ាស៊ី ៖ ហើយមុខសញ្ញាដែលធ្វើ មុខព្រួញដែលត្រូវចុះធ្វើដូចគ្នាៗក៏ខុសៗគ្នា?

គូ ៖ ខុសគ្នា ខ្ញុំមុនដំបូងគេឲ្យជីកប្រឡាយ ដល់ជីកប្រឡាយត្រូវខែជីកប្រឡាយ ដល់ក្រោយមក ទៀតគេឲ្យក្រុមខ្ញុំដាំបន្លែ ខ្ញុំទៅដាំនៅលើភ្នំជ្រោះចាន់ ដាំលើភ្នំ ដាំពោត ដាំត្រសក់ គ្រប ក្រុមខ្ញុំនឹង ដាំទៅដេកនៅព្រៃ ។

រ៉ាស៊ី ៖ ក្រុមមីង ក្រុមទីប៉ុន្មាន?

គូ ៖ មិនដឹង ក្រុមទី៦ ។

រ៉ាស៊ី ៖ មីងក្រុមទី៦?

គូ ៖ ចា៎ស!

រ៉ាស៊ី ៖ អីចឹងមិនមែនមាន៥ក្រុមទេ អាចថា៦ លើសពី៦?

គូ ៖ ចា៎ស! ក្រុមខ្ញុំក្រុមចុងគេ ខ្ញុំរវល់តែឈឺពេកគេឲ្យ ដាំបន្លែ ក្រុមចុងគេបង្អស់ហើយ ក្រុមខ្ញុំ ច្រើនតែអ្នកឈឺ ក្រុមខ្ញុំអត់សូវមានអ្នកជាទេ ។

វ៉ាស៊ី ៖ អីចឹងមីងក្រុមអី៦?

គូ ៖ ចាស!

វ៉ាស៊ី ៖ នៅពេលដែលចូលធ្វើការ ដូចថាមីងដែលធ្វើបានគ្រប់ផែនការដែលអង្គការថ្នាក់លើដាក់ឲ្យទេ?

គូ ៖ មិនដែលបាន ធ្វើមិនបានទេ ។

វ៉ាស៊ី ៖ ធ្វើអត់ដែលបានអីចឹង មានរឿងអីកើតឡើង?

គូ ៖ មាន គេស្ដី១អីចឹងទៅ គេស្ដីធ្វើឲ្យបានអីចឹង ។

វ៉ាស៊ី ៖ គេស្ដីឲ្យ គេគ្រាន់តែស្ដីឲ្យ គេអត់មានធ្វើអីទៀត ដូចអត់មានបញ្ហាឲ្យយើងធ្វើអី?

គូ ៖ គេបញ្ហាអីចឹង បើពេលយើងធ្វើអានឹងមិនបានគ្រប់ចំនួនរបស់គេ គេដកឲ្យយើងទៅជីកប្រឡាយម៉ាបួន២បួន បើយើងធ្វើបានគ្រប់ចំនួន អានឹងគេមិនដកទេ គេនៅឲ្យយើងជីក ។

វ៉ាស៊ី ៖ ឲ្យនៅជីកទៀត?

គូ ៖ ចាស! ដល់ពេលខែវស្សាគេឲ្យដកសំណាប គេកំណត់ឲ្យដកអីចឹង ដកស្ទូងអីចឹង ក្រុមខ្ញុំប៉ុន្មានស្ទូងម៉ាហិចតាអីចឹង ដកប៉ុន្មានស្នឹក កំណត់ឲ្យ ។ តែក្រុមខ្ញុំក្រុមអន់ជាងគេ ព្រោះឈឺច្រើន ។

វ៉ាស៊ី ៖ អីចឹងការងារក៏ធូរតាមនឹងដែរ ព្រោះយើងឈឺច្រើន?

គូ ៖ តែយើងឈឺច្រើន គេឲ្យយើងបន្ធូឲ្យយើងដែរ បន្ធូប៉ុនចំណីហូបមិនបានគ្រប់គ្រាន់ទេ យើងនៅចំការអីចឹង ពេលបើកអង្ករមកអត់គ្រប់អីចឹង យើងដាំពោត ដាំអីបាន យើងហូបពោត ហូបអីលាយគ្នាអីចឹង ។ បំពេញឲ្យតែឆ្អែត អារឿងចែកឲ្យគ្រប់អត់គ្រប់ទេ ព្រោះក្រុមយើងវាអត់សូវមានកម្លាំងធ្វើនឹងគេ ។

វ៉ាស៊ី ៖ ចុះក្រុម៩មីងស្គាល់ឈ្មោះទេ អ្នកណាគេជាប្រធាន?

គូ ៖ មិនស្គាល់គេទេ ភ្លេចអស់ហើយ យូរពេក ។

វ៉ាស៊ី ៖ អ្នកនៅស្រុកភូមិយើងដែរ?

គូ ៖ គ្មានទេ ។

វ៉ាស៊ី ៖ អាចថាអ្នកនៅភូមិផ្សេង?

គូ ៖ មាននៅអីសាអូរមួយ បងឆឹង១ ។

វ៉ាស៊ី ៖ គាត់នៅក្រុមណា?

គូ ៖ បងឆឹង ដឹងនៅក្រុមទីប៉ុន្មានដែរ យូរពេកហើយប្អូន៣០ជាងហើយ ហើយអីរវល់តែឈឺ ។

វ៉ាស៊ី ៖ តែគាត់សុទ្ធតែជាមេក្រុម?

គូ ៖ ចាស! គាត់ក្រុមដែរ ។

វ៉ាស៊ី ៖ សព្វថ្ងៃគាត់នៅរស់ដែរ?

គូ ៖ បងឪងនឹងនៅរស់ មិនដែលជួបផង ។

វ៉ាស៊ី ៖ អត់នៅរស់នៅនេះ?

គូ ៖ អត់ទេ ស្រុកគាត់នៅតាអូរ ។

វ៉ាស៊ី ៖ ពេលកំពុងធ្វើការ មីងមានសង្កេតថាសមាជិកក្រុមរបស់មីងអាចថាមានជម្ងឺ ត្រូវខ្យល់ដួលនៅកន្លែង?

គូ ៖ មាន ដល់ពេលធ្វើអីចឹងខ្យល់ដាំ ខទាហរណ៍ដាំ ចូកចំការ ដាំបន្លែដាំអី តែខ្យល់នាំមកកន្លែងចាប់ខ្យល់ កោសខ្យល់ ។

វ៉ាស៊ី ៖ ចុះមានអ្នកស្លាប់ទេ?

គូ ៖ ក្រុមខ្ញុំមិនដែលមានស្លាប់ទេ ។

វ៉ាស៊ី ៖ ចុះមានគេធ្វើទារុណកម្ម ធ្វើអីទៅលើគាត់?

គូ ៖ មិនដែលផង ដែលដាក់ទណ្ឌកម្មឲ្យធ្វើអីធ្វើឲ្យបាន បើយើងធ្វើមិនបានគេស្តីគេនេះ រករឿង រកអីចឹង ។

វ៉ាស៊ី ៖ ហូបចុកម៉េចដែរ ឆ្អែតទេ?

គូ ៖ ហូបចុកមិនឆ្អែតដូចខ្ញុំនិយាយអីចឹង គេចែកអង្ករថាខទាហរណ៍ថា១៥-១៦-២៦នាក់ គេឲ្យអង្ករក្នុងម៉ាថ្ងៃនឹង គិតតែម្នាក់២នាក់ម៉ាកំប៉ុង ដល់យើងហូបមិនឆ្អែតយើងរកគល់ចេកគ្រាប់គល់ល្ហុងអីលាយ ។

វ៉ាស៊ី ៖ តាមពិតដាក់ស្ងែង គេគិតម៉េចឲ្យទៅរបបហូបចុក?

គូ ៖ របបហូប គេឲ្យ២នាក់ម៉ាកំប៉ុង ។

វ៉ាស៊ី ៖ ២នាក់ម៉ាកំប៉ុង តាំងពីដំបូងរហូតដល់ចប់?

គូ ៖ ចាស! ក្នុងម៉ាថ្ងៃ ។ ដល់ក្រុមយើងនឹងហូបមិនឆ្អែត យើងរកអីដាក់ហូបទៀតទៅ បើមិនលាយមានប៉ុន្មានចែកគ្នាហូបប៉ុននឹង គេវាស់ឲ្យយើងហូប គេកំណត់ឲ្យវាស់ ។

វ៉ាស៊ី ៖ អីចឹងបានហូបបាយដែរ?

គូ ៖ ចាស! បាយ ប៉ុនបាយមិនគ្រប់គ្រាន់ ។

វ៉ាស៊ី ៖ មានអ្នកឈឺមានអីដែរ?

គូ ៖ ឈឺមាន ។

វ៉ាស៊ី ៖ ហើយកូនក្រុមរបស់មីងនឹង អ្នកប្រជាជននៅក្នុងភូមិនេះ ឬប្រជាជនថ្មី ប្រជាជនជម្លៀស?

គូ ៖ ភូមិខ្ញុំមិនដែលនៅជាមួយពួកថ្មី ។

រ៉ាស៊ី ៖ ចុះមីងមានដែលឃើញពួកថ្មី?

គូ ៖ គ្រាន់ឃើញមក កាលពីរដ្ឋប្រហារហើយមក ដល់ពេលនេះគេបញ្ជូនទៅលើ គ្មានបាននៅជាមួយគ្នាណា ។

រ៉ាស៊ី ៖ ហើយចុះមីងធ្វើដល់ពេលណា បានគេឲ្យមីងទៅនៅសោម?

គូ ៖ ដល់ពេលខ្ញុំទៅនៅក្រុម គេការ ។

រ៉ាស៊ី ៖ ការ?

គូ ៖ គេឲ្យសំពះ ប្ដេជ្ញា ។

រ៉ាស៊ី ៖ អូ! មីងការនៅក្នុងជំនាន់នឹងដែរ?

គូ ៖ ចាស!

រ៉ាស៊ី ៖ ការនឹងការរបៀបម៉េច?

គូ ៖ គេច្រើនសំពះឲ្យយើងប្ដេជ្ញានិយាយថា ឧទាហរណ៍ដូចមួយគេដាក់ឈ្មោះយើងការ២នាក់អីចឹង កាលថ្ងៃខ្ញុំការនឹង ៥៥គូ ។

រ៉ាស៊ី ៖ ៥៥គូ?

គូ ៖ ចាស!

រ៉ាស៊ី ៖ សុទ្ធតែអ្នកនារីកងចល័ត?

គូ ៖ កងចល័ត ខ្ញុំការជាមួយ ដល់ប្ដីខ្ញុំកូនឪគេធ្វើប៉ូលីស ហើយឪខ្ញុំមេភូមិគេគូឲ្យការជាមួយគ្នា មេភូមិពីជំនាន់សម្ដេចសីហនុ ហើយឪគេធ្វើប៉ូលីសពីជំនាន់នឹងដែរ ។

រ៉ាស៊ី ៖ មិនមែនជំនាន់លន់ នល់ទេ ជំនាន់ស្ដេចសីហនុ?

គូ ៖ ជំនាន់ស្ដេចសីហនុ គេយកប្រវត្តិរូបអីចឹង ។

រ៉ាស៊ី ៖ គេដឹងប្រវត្តិរូបនឹងដែរ?

គូ ៖ ចាស! ការឲ្យសំពះឲ្យ ប្ដេជ្ញាហ្នឹង ។

រ៉ាស៊ី ៖ មានគេរើសអីចឹងដែរ?

គូ ៖ បើមិនរើសឲ្យអីចឹង ឧទាហរណ៍ដូចយើង ឪធ្វើប្រធានភូមិអីចឹង គេម៉ាខាងទៀតគេយកឪធ្វើប៉ូលីស ឲ្យតែជាប់និន្នាការពីជំនាន់មុនគេដាក់តាម ហើយអាអ្នកម៉ែឪមិនធ្វើគេក្រអានឹងគេដាក់នៅនិន្នាការល្អ ។

រ៉ាស៊ី ៖ ហើយអត់មានរឿងអីកើតឡើង មីងការហើយ ដូចថាគេដឹងប្រវត្តិរូបមីងថា?

គូ ៖ ដល់ពេលការហើយ គេឈប់ឲ្យធ្វើអី ។

វ៉ាស៊ី ៖ នៅឆ្នាំណា មីងការឆ្នាំណា?

គូ ៖ ការ មុនយើងរំដោះបាន២ឆ្នាំ ។

វ៉ាស៊ី ៖ មុនរំដោះ២ឆ្នាំ?

គូ ៖ ចា៎ស!

វ៉ាស៊ី ៖ អីចឹងឆ្នាំ៧៧ ៧៦ ។

គូ ៖ មុនយើងរំដោះបាន ខាងសម្ដេចហ៊ុន សែន រំដោះបាន ។

វ៉ាស៊ី ៖ ៧៧?

គូ ៖ ហ្នឹងហើយ ខ្ញុំការមុននឹង ការកាលនឹងបាន២ឆ្នាំរំដោះ ។

វ៉ាស៊ី ៖ ចុះមីងការហើយលែងនៅកងចល័តទៀតហើយ?

គូ ៖ លែងនៅ ។

វ៉ាស៊ី ៖ គេឲ្យទៅនៅណា?

គូ ៖ គេឲ្យទៅនៅសហករណ៍ ។

វ៉ាស៊ី ៖ ទៅនៅសហករណ៍វិញ សហករណ៍ណា?

គូ ៖ ចា៎ស! នៅរាមអណ្ដើក នៅកងចល័ត នៅសហករណ៍រាមអណ្ដើក ។

វ៉ាស៊ី ៖ ទៅជាមួយគ្រួសារមីងដែរ?

គូ ៖ ចា៎ស! ទៅជាមួយគ្រួសារ ។

វ៉ាស៊ី ៖ ទៅដល់នោះ មីងធ្វើអីទៅ ទៅដល់នោះ?

គូ ៖ អត់មានធ្វើអី ទៅដាំបន្លែ ដាំអីស្ទូងដកធម្មតា ។

វ៉ាស៊ី ៖ កាលនឹងអ្នកណាប្រធានសហករណ៍ នៅរាមអណ្ដើក?

គូ ៖ តាម៉ូត ស្លាប់អស់ ។

វ៉ាស៊ី ៖ ទៅដល់នោះគេឲ្យនៅជាមួយគ្នា?

គូ ៖ មិននៅជាមួយគ្នាអី ដូចថាម៉ាអាទិត្យគេឲ្យមកគេមកនៅជាមួយគ្នាម៉ាថ្ងៃ ។ គេផ្នែកប្រុសគេទៅ ធ្វើការខាងប្រុស យើងស្រីៗធ្វើការស្រី ។

វ៉ាស៊ី ៖ គ្រួសារមីងធ្វើអី?

គូ ៖ មុនដំបូងធ្វើទ័ព មុនការធ្វើទ័ពៗប៉ុលពតនឹង ។

វ៉ាស៊ី ៖ ហើយមានដែលឃើញគ្នាពីមុនមក?

គូ ៈ អត់ទេពូ មិនដែលឃើញ ។

រ៉ាស៊ី ៈ អន្ដការគេ?

គូ ៈ គេដាក់ឲ្យឈ្មោះមកអីចឹង គេហៅខ្ញុំនៅកងចល័តក្រុមខ្ញុំអីចឹង មានឈ្មោះគេគូគេហៅ គេមិនប្រាប់យើងមុនទេ ។ ឧទាហរណ៍ដូចថាថ្ងៃនឹង យប់នឹង គេឲ្យយើងប្ដេជ្ញាគេប្រាប់ម៉ោង១២ គេ ប្រាប់ឲ្យយើងទៅមូលគ្នា ។

រ៉ាស៊ី ៈ កាលទៅប្ដេជ្ញា ទៅប្ដេជ្ញានៅណានៅផ្ទះរបស់មីង ឬក៏នៅកន្លែងផ្សេង?

គូ ៈ កន្លែងមន្ទីរស្រុកគេ

រ៉ាស៊ី ៈ ទៅមន្ទីរស្រុកម៉ង?

គូ ៈ កន្លែង ចាស៎! កន្លែងប្រធាន កន្លែងមន្ទីរស្រុកគេ ។

រ៉ាស៊ី ៈ កាលនឹងមន្ទីរស្រុកគេនៅខាងណា?

គូ ៈ នៅអន្ដរុនៗត្រពាំងខ្ទៅៗ ។

រ៉ាស៊ី ៈ អន្ដរុន? នៅណាវិញខ្ទៅ ត្រង់នឹង?

គូ ៈ រាមអណ្ដើក ។

រ៉ាស៊ី ៈ រាមអណ្ដើក?

គូ ៈ ចាស៎!

រ៉ាស៊ី ៈ អន្ដរុននេះឈ្មោះភូមិ?

គូ ៈ ភូមិអន្ដរុន ប៉ុនឃុំរាមអណ្ដើក ។

រ៉ាស៊ី ៈ ហើយអ្នក៥៤គូផ្សេងទៀតនឹង អ្នកកងចល័តនៅក្នុងស្រុកទាំងអស់?

គូ ៈ នៅក្នុងស្រុកទាំងអស់ ដូចថាប៉ុន្មាន៥-៦ក្រុមគេរើសគ្រប់គ្នា រើសឧទាហរណ៍ថាឪខ្ញុំប្រធានភូមិពីជំនាន់សីហនុ ហើយប្ដីខ្ញុំឪគេធ្វើប៉ូលីសនៅប៉មពន្លៃជំនាន់សីហនុដែរ ហ្នឹងគេរើសឲ្យត្រូវៗគ្នាអីចឹង ។

រ៉ាស៊ី ៈ អ្នកដែលអត់មានជាប់អីសោះ រៀបជាមួយអ្នកអត់មានជាប់អី?

គូ ៈ ចាស៎! អត់មានជាប់ ដូចខ្ញុំមានមេធ្វើប្រធាន ធ្វើអីពីជំនាន់សីហនុអីចឹង គេដាក់អ្នកនិន្នាការមិនល្អ ដោយមិនល្អ ។

រ៉ាស៊ី ៈ មីងគេចាត់ចូលក្នុងអ្នកដែលនិន្នាការអត់ល្អ?

គូ ៈ ខ្ញុំមិនល្អ ព្រោះអី ។

រ៉ាស៊ី ៈ បើសិនជាល្អ មីងអាចថាឡើងដល់ស្រុកដល់អី?

គូ ៖ ចាស! បើខ្ញុំល្អ បានគេឲ្យខ្ញុំធ្វើធំហើយ ព្រោះខ្ញុំអត់ល្អ មា ហើយឪខ្ញុំ ។

វ៉ាស៊ី ៖ អីចឹងបាននៅត្រឹមក្រុមនឹងទៅ?

គូ ៖ ចាស!

វ៉ាស៊ី ៖ ហើយមីងទៅនៅនឹងបានប៉ុន្មានឆ្នាំទៅ ទៅនៅភូមអណ្តើក?

គូ ៖ ទៅនៅមិនបានមួយឆ្នាំផង វិលតែមិត(រត់) ។

វ៉ាស៊ី ៖ មិត(រត់) ទៅខាងណាវិញ?

គូ ៖ ទៅឈូកទៅអី ។

វ៉ាស៊ី ៖ អូ! ទៅខាងកំពត?

គូ ៖ ចាស!

វ៉ាស៊ី ៖ ម៉េចបានមិត(រត់) វៀតណាមវ៉ៃចូល?

គូ ៖ វៀតណាមវ៉ៃចូល គេគៀរយើងទៅ ។

វ៉ាស៊ី ៖ គៀរទៅ?

គូ ៖ ចាស!ដូចថា គៀរយកវ៉ៃដល់ទម្លាប់ គេប្រាប់យើងថាឲ្យនាំគ្នាមិត(រត់) ទៅ ហើយយើង បរទេះ បរអីមិត(រត់) ទៅ អ្នកមានរទេះ អ្នកអត់រែកអីចឹងទៅ ។

វ៉ាស៊ី ៖ នៅកំឡុងពេលនឹងដែលមីងធ្វើការរហូតដល់បានរៀបការ តើមីងមានបានឃើញទិដ្ឋភាពកើតឡើង ឧទាហរណ៍ថាឃើញការសម្លាប់មនុស្ស ឃើញការធ្វើទារុណកម្ម ឬក៏អាចថាធ្វើការទៅ ឃើញ មីងធ្លាប់ឃើញ?

គូ ៖ នៅកងចល័តគ្មានដឹងអីទេ បើសិនគេនៅតាមភូមិបានៗដឹង ។

វ៉ាស៊ី ៖ តាមភូមិដឹងវិញ?

គូ ៖ ចាស!

វ៉ាស៊ី ៖ នៅកងចល័តអត់ដឹងទេ?

គូ ៖ កងចល័ត អ្នកថ្មីអ្នកអីមក ក៏ខ្ញុំនៅកងចល័តនោះគ្មានដឹងទេ ។

វ៉ាស៊ី ៖ ចុះនៅនេះ ដូចថាមានគេបំផ្លាញវត្តអារាម បំផ្លាញអីមានទេ?

គូ ៖ មានតើ វត្តកំពែងនឹង គេវ៉ៃអស់ ។

វ៉ាស៊ី ៖ វត្តកំពែង?

គូ ៖ គេវ៉ៃវិហារវ៉ៃអីចឹង ដូះខ្ញុំវ៉ាន់គេរុះយកទាំងអស់ ។

វ៉ាស៊ី ៖ ចុះវិហារនៅវត្តកំពែងនឹងវ៉ៃចោលម៉ង?

គូ ៖  រេីវ៉ចោល ។

វ៉ាស៊ី ៖ គេយកធ្វើអីវិញទៅ?

គូ ៖  ដឹង រេីវ៉ចោលអីចឹង មិនដឹងគេយកធ្វើអីស្អី ។

វ៉ាស៊ី ៖ អ្នកណាអ្នករេីវ៉?

គូ ៖  ប្រធានភូមិគេ ។

វ៉ាស៊ី ៖ ឈ្មោះអីដែរ ប្រធានភូមិនឹង?

គូ ៖  មិនដឹងអ្នកណាគេអ្នករេីវ៉ទេ គ្រាន់ថាប្រធានភូមិកំពែងនឹង តែនេះពូគុនគាត់ធ្វើប្រធានភូមិហាន់ទានឹង ហើយមិនដឹងអ្នកណាអ្នករេីវ៉ ។

វ៉ាស៊ី ៖ អីចឹងគាត់នឹងជាអ្នកបញ្ជា?

គូ ៖  ចា៎ស! បញ្ជាគេបញ្ជាពីលើមក គាត់ធ្វើតាមគេ តែគេថាឲ្យរេីវ៉ គាត់រេីវ៉ គាត់មិនមែនបញ្ជាថាចេះត្រឹមគាត់ប្រធានភូមិនឹង ។

វ៉ាស៊ី ៖ មីងបានឃើញទេ បានឃើញគេរេីវ៉?

គូ ៖  ខ្ញុំមិនបានឃើញទេ គ្រាន់ឮគេនិយាយដែរនឹង ប៉ុនដល់ពេលហើយទៅ ឃើញបាក់បែកមែន ។

វ៉ាស៊ី ៖ ដឹងមូលហេតុអី? ក្រោយមកគេយកទីតាំងវិហារនឹងធ្វើអីវិញ?

គូ ៖  មិនដឹងវត្តកំពែងនឹង ដឹងគេយកធ្វើអី មិនដឹងផង ដល់ពេលដើរនៅតែពាស ទៅនៅកងចល័តលែងដឹង ដល់ពេលការហើយទៅនៅតាមគ្រួសារ ។

វ៉ាស៊ី ៖ ចុះអានឹងកើតឡើងឆ្នាំណា ដែលគេរេីវ៉វិហាររេីវ៉អីនឹង?

គូ ៖  ដឹងឆ្នាំប៉ុន្មាន ។

វ៉ាស៊ី ៖ បែក៧៥ហើយយូរដែរ?

គូ ៖  ៧៥ហើយយូរដែរ ។

វ៉ាស៊ី ៖ ប្រហែលជាងប៉ុន្មានឆ្នាំ? អាចថាគិតមើលនៅក្នុងឆ្នាំនឹងដដែល ឬក៏ឆ្នាំក្រោយមកទៀត?

គូ ៖  វ៉ារដ្ឋប្រហារហើយ២ឆ្នាំ ។

វ៉ាស៊ី ៖ រដ្ឋប្រហារ៧០នឹង?

គូ ៖  ចា៎ស!

វ៉ាស៊ី ៖ រដ្ឋប្រហារទម្លាក់សម្ដេចនឹង?

គូ ៖  ទម្លាក់សម្ដេចនឹង ដល់ពេលខ្មែរក្រហមមក ។

វ៉ាស៊ី ៖ ខ្មែរក្រហមចូលមករេីវ៉ម៉ាសារទៀតនៅឆ្នាំ៧៥?

គូ ៖ ចាស៎! ហ្នឹងហើយ ។

វ៉ាស៊ី ៖ អីចឹងពីនឹងមកទៀត ២ឆ្នាំ?

គូ ៖ ដល់ពេលអាខ្មែរក្រហមគេរំដោះបាន អានឹងគេរើកាលនឹង ។

វ៉ាស៊ី ៖ បាទ! កាលនឹង២ឆ្នាំក្រោយនឹង ឬក៏?

គូ ៖ ២ឆ្នាំក្រោយ ។

វ៉ាស៊ី ៖ អាចថានៅក្នុងឆ្នាំ៧៧? ហើយផ្ទះសម្បែង?

គូ ៖ ផ្ទះសម្បែង ផ្ទះខ្ញុំវ៉ាន់គេរូសយកធ្វើចាំងអស់ គេយកធ្វើរោងសហករណ៍ដាំបាយហូប ។

វ៉ាស៊ី ៖ ចុះផ្ទះមីងគេរូស?

គូ ៖ ចាស៎! គេរូស ។

វ៉ាស៊ី ៖ ពេលដែលគេរូស មីងនៅនឹង?

គូ ៖ គេប្រមូលឲ្យទៅកងចល័តហើយ ។

វ៉ាស៊ី ៖ ហើយលោកយាយ?

គូ ៖ ហើយម៉ែខ្ញុំគេឲ្យទៅត្បាញតាមក្រុមចាស់ៗ ។

វ៉ាស៊ី ៖ ហើយពេលគេរូស គេអត់ប្រាប់យើង?

គូ ៖ អត់ទេ អត់ប្រាប់ គេរូសៗ ។

វ៉ាស៊ី ៖ កាលនឹងប្រធានភូមិនឹងមករូសដែរ?

គូ ៖ ភូមិតាម៉េង មិនដឹងអ្នកណារូស ប៉ុនគេរូសធ្វើរោងសហករណ៍ភូមិតាម៉េង ។

វ៉ាស៊ី ៖ អត់បានឃើញហេតុការណ៍នឹងផ្ទាល់ទេ?

គូ ៖ អត់ ចុះយើងចេញអស់ហើយ គេឲ្យទៅនៅក្រុមចល័តនារី កងចល័តនឹង ហើយម៉ែខ្ញុំគេឲ្យទៅត្បាញ ។

វ៉ាស៊ី ៖ ផ្ទះមីងនៅក្នុងភូមិនឹងដដែល?

គូ ៖ ចាស៎!

វ៉ាស៊ី ៖ ភូមិអីគេ?

គូ ៖ ភូមិតាម៉េង កាលនឹងនៅតាម៉េង ។

វ៉ាស៊ី ៖ អូ!តាម៉េង?

គូ ៖ ដល់ពេលចុះមកខ្ញុំមកនៅនឹង ។

វ៉ាស៊ី ៖ ភូមិតាម៉េងក្នុងឃុំកំពែងនឹងដែរ?

គូ ៖ យុំនឹងគ្នា ។

រ៉ាស៊ី ៖ មីងស្គាល់អ្នករូសផ្ទះមីងទេ?

គូ ៖ មិនដឹង ចុះកាលនឹងជំនាន់គាញ៉ៀបនឹង ។

រ៉ាស៊ី ៖ អាចថាញ៉ៀបនឹងជាអ្នកបញ្ជាឲ្យរូស?

គូ ៖ ចា៎ស!

រ៉ាស៊ី ៖ មូលហេតុអីបានគេរូសផ្ទះនឹង?

គូ ៖ គេរូសយកធ្វើ ។

រ៉ាស៊ី ៖ ធ្វើសហករណ៍?

គូ ៖ សហករណ៍ ដូចថាយើងខ្លាចគេអីចឹង យើងខ្លាចគេយកម៉ែឪខ្លួនយើងយកទៅសម្លាប់ យើងចេះប្រគល់ឲ្យគេទៅ ។

រ៉ាស៊ី ៖ គេស្នើដែរ?

គូ ៖ ថាចេះ គេមិនសុំយើង ទោះយើងមិនឲ្យក៏គេរូសដែរ បើគេរូសក៏យើងអត់ហ៊ាននិយាយអីដែរ ផ្ទះណាក៏ដោយ ផ្ទះនឹងក៏ដោយ ។

រ៉ាស៊ី ៖ គេរូសផ្ទះច្រើនទេ ដែលគេរូស?

គូ ៖ ច្រើនផ្ទះ ។

រ៉ាស៊ី ៖ ក្នុងពេលតែមួយនឹង ឬក៏អាចថា?

គូ ៖ ដូចថាគេយកទៅធ្វើកន្លែងសហករណ៍គេមួយ ផ្ទះប៉ុន្មានគ្រប់គេរូសប៉ុននឹងទៅ ។

រ៉ាស៊ី ៖ រូសនៅនឹង រូសផ្ទះមីងនឹងក្រោយគេវ៉ៃវត្តចោល ឬមុន?

គូ ៖ មុន ។

រ៉ាស៊ី ៖ មុនយូរដែរ?

គូ ៖ មុនយូរដែរ ។

រ៉ាស៊ី ៖ ចុះនៅក្នុងជំនាន់នឹងមានអ្នកពោះធំមានអីដែរ?

គូ ៖ មានតើ ។

រ៉ាស៊ី ៖ អត់អី?

គូ ៖ អ្នកពោះធំគេមានពេទ្យគេឲ្យយើងមកមើលកូនង៉ែត គេមិនឲ្យនៅកូនង៉ែតនៅផ្ទះ ។

រ៉ាស៊ី ៖ មាននេះដែរ?

គូ ៖ ពេទ្យគេដែរ កន្លែងពេទ្យគេវត្តភ្នំ ។

រ៉ាស៊ី ៖ វត្តភ្នំ?

គូ ៖ ចាស! គេដាក់មន្ទីរពេទ្យ វត្តភ្នំ ហើយវត្តជីទាក់ គេដាក់ធ្វើមន្ទីរពេទ្យ អ្នកពោះធំនឹងគេឲ្យទៅកូនង៉ែតនឹង អ្នកកើតមិនរួច គេឲ្យបញ្ជូនទៅពោធិ៍តាអត្ត ហើយមន្ទីរពេទ្យគេនឹង គេមិនឲ្យយើង នៅកូនង៉ែតតាមផ្ទះទេ។

រ៉ាស៊ី ៖ គេខ្វាចដែរ?

គូ ៖ ចាស!

រ៉ាស៊ី ៖ ចុះក្មេងៗ ឲ្យនៅជុំគ្នាជាមួយកុមារ?

គូ ៖ អត់ទេ ឲ្យនៅគេចល័តនៅក្មេងៗគេឲ្យនៅក្មេងជាមួយក្មេង គេមិនឲ្យ។

រ៉ាស៊ី ៖ អូ! នៅកងក្មេងៗ?

គូ ៖ ចាស! កងកុមារគេអីចឹង មានគ្រូ មានអីគេនៅគ្រប់គ្រងក្មេង។

រ៉ាស៊ី ៖ ចុះមីងថាជម្លៀសនោះ ជម្លៀសទៅឆ្នាំណាទៅ ជម្លៀសទៅសោមនោះ? ស្តាប់មីងមិញ ដូចជាអត់មានជម្លៀសទេ?

គូ ៖ គេមិននេះទេ ដូចថាគេរើសចេះ រើសគ្រួសារធ្វើទ័ពអីចឹង គេរើសឲ្យទៅនៅសោមម្តុំ គ្រួសារយុទ្ធជន។ ខ្ញុំប្អូនមួយធ្វើទ័ព ប្រុសមួយស្លាប់នឹង។

រ៉ាស៊ី ៖ គេឲ្យទៅនៅនឹង?

គូ ៖ ឲ្យទៅនៅនឹង។

រ៉ាស៊ី ៖ ហើយអត់មកនៅនេះវិញ ឬមកវិញ?

គូ ៖ អត់ទេ ដល់ពេលដែលយើងរត់ទៅលើទៅនៅនឹងហើយរត់ៗទៅលើអីចឹង ដល់ខាងយើងរំដោះបាន សម្តេចហ៊ុន សែន រំដោះបាននឹងបានមកនៅស្រុកយើងវិញ។

រ៉ាស៊ី ៖ បានន័យថា បន្ទាប់ពីមីងធ្វើកងចល័តហើយ មីងរៀបការហើយ មីងទៅនៅរាមអណ្តើក?

គូ ៖ ចាស!

រ៉ាស៊ី ៖ បាន មីងទៅនៅសោម?

គូ ៖ នៅសោម។

រ៉ាស៊ី ៖ គេមិនមែនជម្លៀស គេឲ្យទៅនៅ?

គូ ៖ គេជ្រើស។

រ៉ាស៊ី ៖ គេជ្រើសឲ្យទៅនៅ?

គូ ៖ ចាស! ជ្រើស។

វ៉ាស៊ី ៖ មីងអត់ដឹងមូលហេតុអីទេ?

គូ ៖ មិនដឹង ឮគេថាគេរើសអីចឹង គ្រួសារយុទ្ធជន ខ្ញុំការប្ដីខ្ញុំគេធ្វើទ័ពដែរ ធ្វើទ័ពនៅកន្លែងស្រុកទ័ព ស្រុកគេ ដូចថាគេវៃត្រង់ណា ទ័ពស្រុកនឹងគេយកទៅដាក់កន្លែងវៃ ។ វាវរល់តែមិត(រត់)ម៉ាផ្ទះ ។

វ៉ាស៊ី ៖ ហើយប្រធានឃុំញ៉ៅបនឹង ជាអ្នកជម្លៀស ជាអ្នកឲ្យទៅ?

គូ ៖ ចា៎ស!

យាយ៖ ខ្ញុំពាឆ្នាំប៉ុន្មានខែ ខ្ញុំស្មានតែម៉ាខែ?

វ៉ាស៊ី ៖ លឿនយាយ?

យាយ៖ លឿន វាវង្វេងអស់គ្មានដឹងអី វង្វេងវាស្ដាយរបស់ចិញ្ចឹមកូន ស្ដាយស្រែផង ឥឡូវនៅយំស្ដាយ ។

វ៉ាស៊ី ៖ លោកយាយនៅតែស្ដាយដែរ?

យាយ៖ ចុះស្រែម៉ែចែកផង ស្រែទិញផង ហើយគោម៉ានឹមរទេះមួយ ហើយផ្ទះទៀតអស់ ។

វ៉ាស៊ី ៖ ចុះមីងដែលឃើញគេចាប់ចងមនុស្ស ចាប់អី?

គូ ៖ ខ្ញុំមិនដែលនៅនេះមិនដឹង នៅកងចល័ត ដល់អ្នកគេនៅតាមផ្ទះបានគេ ។

វ៉ាស៊ី ៖ ចុះនៅតាមកងចល័តមីងសុទ្ធតែស្រីៗ ចុះដូចថាមានរឿងដូចថាការចាប់រំលោភកើតឡើង?

គូ ៖ មានដូចថាស្រឡាញ់គ្នាអីចឹងទៅ វាស្រឡាញ់គ្នា វាមានដែរ ស្រឡាញ់ជាមួយយុទ្ធជន ដល់ពេលយើងស្រឡាញ់ គេហៅយើងប្រជុំគេឲ្យខុទាហរណ៍ដូចខ្ញុំ ស្រឡាញ់គ្នាជាមួយអ្នកណាម្នាក់ឲ្យយើងឡើងនិយាយ ដល់ពេលស្រឡាញ់ថា យើងស្រឡាញ់គ្នាខុសច្បាប់ ឲ្យយើងហៅមុខនារីរាប់រយ ។

វ៉ាស៊ី ៖ គេអត់ធ្វើទណ្ឌកម្មអីលើយើង ប៉ុន្តែឲ្យយើងឡើងនិយាយ?

គូ ៖ ទណ្ឌកម្ម ដូចគេធ្វើអីចឹង បើគេបកអាក្រាធយើងមនុស្សរាប់រយ ។

វ៉ាស៊ី ៖ មានដែលនៅក្នុងសមាជិករបស់មីង?

គូ ៖ មានដែល ។

វ៉ាស៊ី ៖ ធ្វើការជាប់នៅមានលួចស្រឡាញ់គ្នា កើតដែរ?

គូ ៖ ចុះមានទៅធ្វើនឹងមិនមែនពេលយើងទៅដាំបន្លែ ក៏មានក្រុមយុវជននឹងគេម៉ាក្រុមដាំបន្លែដូចយើងអីចឹងដែរ ប៉ុនវានៅក្រុមខុទាហរណ៍ថានៅកន្លែងនឹងផ្ទះមួយក្រុមនារីអីចឹង ក្រុមយុវជនប្រហែលផ្ទះប្រធានភូមិ ពេលទៅធ្វើវាអាចជួនគ្នា ។

រ៉ាស៊ី ៖ ជួបគ្នា?

គូ ៖ ចា៎ស!

រ៉ាស៊ី ៖ ប៉ុនចាប់រំលោភអីអត់មាន?

គូ ៖ អត់មាន ។

រ៉ាស៊ី ៖ កម្មាភិបាលធំៗមកចាប់រំលោភអី?

គូ ៖ ចា៎ស! អត់មាន ។

សេងគា៖ អ៊ីចឹងមីងខ្ញុំសុំសួរចំនុចបន្ថែមបងរ៉ាស៊ីតិច ខ្ញុំឈ្មោះសេងគា ចង់សួរបន្ថែមបន្តិចដែរ ទាក់ទងពីរឿងមីងបានធ្វើប្រធានកងចល័តអ៊ីចឹងមីង?

គូ ៖ ខ្ញុំមិនមែនប្រធានទេ ខ្ញុំសមាជិកគេ ដូចប្រធានក្រុម ។

សេងគា៖ សមាជិកក្រុម ប្រធានក្រុមកងចល័ត?

គូ ៖ ចា៎ស!

សេងគា៖ ហើយមានគ្នា២៦នាក់?

គូ ៖ ចា៎ស!

សេងគា៖ មីងកាលនឹងគេឲ្យធ្វើប្រធានក្រុមកងចល័តនឹងនៅកន្លែងណាដែរ?

គូ ៖ ខ្ញុំនៅឈើជ្រោះចាន់ ។

សេងគា៖ នៅជ្រោះចាន់?

គូ ៖ ចា៎ស!

សេងគា៖ ភូមិអី?

គូ ៖ ភូមិអាលើក កន្លែងជ្រោះចាន់ ។

សេងគា៖ ភូមិជ្រោះចាន់?

គូ ៖ ចា៎ស! កន្លែងចំការ ។

សេងគា៖ ចំការជ្រោះចាន់?

គូ ៖ ចា៎ស!

សេងគា៖ ជ្រោះចាន់នឹងឃុំអីដែរ កំពែងដដែល?

គូ ៖ ឃុំរាមអណ្តើក ។

សេងគា៖ ឃុំរាមអណ្តើកវិញ?

គូ ៖ ចា៎ស!

សេងគាៈ ស្រុកត្រាំកក់ ស្រុកគីរីវង់ដដែល?

គូ ៈ គីរីវង់ ចា៎ស!

សេងគាៈ កាលនឹងនៅ...ឆ្នាំប៉ុន្មាន?

គូ ៈ មិនដឹងឆ្នាំប៉ុន្មាន មុនយើងរត់ម៉ាឆ្នាំ មុនយើងរត់ទៅលើ ។

សេងគាៈ មុនរត់៧៥?

គូ ៈ មុនរំដោះ៧៥ ចា៎ស!មុនរំដោះ៧៥ ។

សេងគាៈ អីចឹង៧៦?

គូ ៈ ចា៎ស!

សេងគាៈ មីងហេតុអីបានគេឲ្យមីងធ្វើប្រធានក្រុមនៅកងចល័តនឹង?

គូ ៈ ចុះគេរើសឲ្យខ្ញុំធ្វើអីចឹង ។

សេងគាៈ ម៉េចបានគេជ្រើស មីងធ្វើការងារល្អឬក៏ម៉េច?

គូ ៈ គេថាយើងធ្លាប់ធ្វើការងារខស្បាហ៍ យើងធ្លាប់ធ្វើនៅផ្ទះយើង ដាំបន្លែដាំអីល្អគេរើសឲ្យយើងធ្វើ ។

សេងគាៈ អ្នកណាគេអ្នកជ្រើសឲ្យមីងធ្វើអានឹង?

គូ ៈ នោះ បងជ្រន ហើយបងខឿន ប្រធានគេលើនឹង ប្រធាននារីស្រុកនឹង ។

សេងគាៈ បងខឿន?

គូ ៈ បងខឿន ។

សេងគាៈ បងខឿន ជ្រន ទាំង៣រើស ឬមានម្នាក់ទៀតរើស?

គូ ៈ ជ្រន ហើយភី ៣នាក់ ។

សេងគាៈ ទាំង៣នាក់រើសមកប្រជុំគ្នារើស?

គូ ៈ ចា៎ស!

សេងគាៈ ចាត់មីងឲ្យរើស?

គូ ៈ គេរើសដូចថាម៉ាចល័តស្រុកនឹង គេរើសប្រធានក្រុមប៉ុន្មាន គេរើសគ្នាគេ ពេលគេប្រជុំគេប្រកាសឈ្មោះយើងថា ដូចឈ្មោះខ្ញុំធ្វើប្រធានក្រុមទីប៉ុន្មានអីចឹងណា ។

សេងគាៈ ហើយគេឲ្យមីងធ្វើនឹង មិញបងគាត់សួរខ្លះហើយ ទាក់ទងគេឲ្យធ្វើការងារតែដាំបន្លែមួយមុខទេឬក៏?

គូ ៈ ដាំន្លែ ។

សេនគា៖ដាំបន្លែ ហើយធ្វើអីទៀត?

គូ ៖ ខែយើងដាំបន្លែ គេឲ្យដាំបន្លែអីចឹងទៅ ដល់ពេលយើងដាំបន្លែនឹងមិនតាមការកំណត់គេ គេដក ឲ្យយើងទៅសកសំណាបស្ទូងអីចឹង ខែវស្សាស្ទូងអីចឹង។

សេនគា៖ដាំបន្លែ ស្ទូង?

គូ ៖ ចា៎ស! ជីកប្រឡាយ។

សេនគា៖ជីកប្រឡាយទៀត មានអីទៀតទេ?

គូ ៖ មានអី ការងារខ្ញុំប៉ុននឹង។

សេនគា៖ ហើយគេឲ្យធ្វើនឹងពីពេលណា ដល់ពេលណាដែលកាលនឹង?

គូ ៖ ពេលធ្វើនឹង មុនយើងរំដោះបាន២ឆ្នាំ។

សេនគា៖ ហើយយើងម៉ាថ្ងៃៗគេឲ្យធ្វើម៉េចដែរ ពីព្រលឹម?

គូ ៖ ពីព្រលឹមអីចឹងចេញទៅដោតស្មៅ ដាំត្រប ដាំពោតអីចឹង។

សេនគា៖ ប្រហែលម៉ោងប៉ុន្មានទៅ ម៉ោង៦ ម៉ោង៧?

គូ ៖ ម៉ោង៧ដល់ម៉ោង១២។

សេនគា៖ ម៉ោង៧ដល់ម៉ោង១២ បានឲ្យហូប?

គូ ៖ ចា៎ស!

សេនគា៖ តែហូបនឹងហូបបាយទេ?

គូ ៖ ម៉ោង១១គេសម្រាក។

សេនគា៖ ហើយម៉ោង១កន្លះចុះទៅវិញ?

គូ ៖ ម៉ោង២ ម៉ោង១ម៉ោង២។

សេនគា៖ ហើយមួយទៀត ខ្ញុំចង់សួរមីងពីរឿងមីងរៀបការគេឈប់ឲ្យធ្វើ?

គូ ៖ ចា៎ស!

សេនគា៖ អីចឹងមីងធ្វើពីនឹងមក ពី៧៦មកធ្វើដល់ប៉ុន្មានបានឈប់ ការ៧៧?

គូ ៖ ចា៎ស!

សេនគា៖ ៧៧រៀបការ?

គូ ៖ ការបានម៉ាឆ្នាំរត់។

សេនគា៖ ការបានម៉ាឆ្នាំ?

គូ ៖ បានម៉ាឆ្នាំបានរំដោះបាន។

សេធគាៈ ការដែលការនឹង អ្នកណាគេអ្នកចាប់មីងឲ្យការជាមួយនឹង មិត្តខឿនឹងដដែល?

គូ ៈ អានឹងខឿន បងខឿន ។

សេធគាៈ នៅពេលដែលចាប់នឹង ហើយអ្នកផ្សេងៗទៀតគេចាប់មកដោយសារអ្នកនឹងជាឪពុកម្តាយ ឬក៏ បងប្អូនធ្លាប់ធ្វើប៉ូលីស មេភូមិ ពីមុនមក ឬក៏ម៉េច?

គូ ៈ បងខឿននឹង គេខ្ញុំសួរចុះ«ចុះបងម៉េចចាំរើសទៅម្នាក់២នាក់» ហើយអាប្តីខ្ញុំមិនដែលស្គាល់ គេរើស ។

សេធគាៈ ហើយគាត់ថាម៉េច?

គូ ៈ ខ្ញុំសួរគាត់ថា គេរើសតាមទិន្នាការ ដូចឯង ឪឯងធ្វើម៉េចភូមិអីចឹងទៅ គេឲ្យប្តីខ្ញុំឪគេធ្វើប៉ូលីស គេរើសតាមខ្សែរយៈអីចឹង អាណាល្អគេដាក់ល្អ ។

សេធគាៈ ប៉ូលីសនឹងទិន្នាការមួយធ្លាក់ចូលទៅក្នុងកាលដែរពួកអត់ល្អ?

គូ ៈ ចាស! ពួកមិនល្អ ហើយឪខ្ញុំធ្វើមេភូមិ ។

សេធគាៈ ហើយ៥០គូ មិញមីងនិយាយមិញ?

គូ ៈ ៥៥គូ ។

សេធគាៈ ៥៥គូសុទ្ធតែអ្នកមិនល្អទាំងអស់?

គូ ៈ មិនទេ មានគេល្អអីចឹង ។

សេធគាៈ មានគេល្អដែរ?

គូ ៈ ចាស! ប៉ុនតែយើង ។

សេធគាៈ គេការលាយគ្នា?

គូ ៈ ការលាយគ្នា ។

សេធគាៈ ហើយពេលដែលការហើយនឹង គេការហើយគេឈប់ឲ្យមីងធ្វើ ហេតុអីបានគេឈប់ឲ្យមីងធ្វើ?

គូ ៈ ចុះបើគេមានប្តីគេឲ្យទៅតាមសហករណ៍តាមប្តី ។

សេធគាៈ សហករណ៍ឈ្មោះរាមអណ្តើក?

គូ ៈ ចាស! រាមអណ្តើក ។

សេធគាៈ ហើយគេឲ្យនៅនឹង គេឲ្យធ្វើអីដែរ ធ្វើធម្មតាដូចជា?

គូ ៈ ធ្វើធម្មតាដូចគេគ្រប់គ្នា ។

សេធគាៈ ធ្វើរហូតដល់បែកប៉ុលពត ឬក៏គេជម្លៀសទៅណាទៀត?

គូ ៖ ដល់ពេលបែកប៉ុលពតនឹង ។

សេងគា៖ ធ្វើនៅភាមរហូត?

គូ ៖ ចាស៎!

សេងគា៖ ចុះមីងថាបងរ៉ាស៊ីស្ងួរថាទៅសោម?

គូ ៖ ទៅសោមនោះកាលពីមុន ។

សេងគា៖ មុនមិនទាន់ការនឹង?

គូ ៖ ចាស៎! មិនទាន់ការ ។

សេងគា៖ បានមកធ្វើប្រធានក្រុមកងចល័តនឹងទេ?

គូ ៖ មិនទាន់បានធ្វើប្រធានកងចល័តនឹងទេ អាទៅនោះ ។

សេងគា៖ អូ!អីចឹងកាលនឹងនៅ?

គូ ៖ ហ្អឹងមិនទាន់បានធ្វើប្រធានក្រុមទេ កាលនឹង ។

សេងគា៖ អីចឹងនៅពេលដែលមីងការហើយ ៧៧នឹង មីងការហើយ កាលនឹងការហើយនៅចុងខែ ឬក៏ដើមខែ៧៧នឹង?

គូ ៖ ចុងខែ ។

សេងគា៖ ចុងខែ៧៧ ជិតចូល៧៨ហើយ?

គូ ៖ ចាស៎!

សេងគា៖ បន្ទាប់មកគេឲ្យមីងឈប់ធ្វើការទាំង២នាក់ រួចគេឲ្យបញ្ជូនមីងទៅ?

គូ ៖ ប្ដីនឹងគេមិនឲ្យឈប់ទេ គេឲ្យនៅធ្វើអីចឹង ពេល ។

សេងគា៖ តែប្ដីមីងនៅនោះគាត់ធ្វើទាហានដដែល ទ័ព?

គូ ៖ ចាស៎! ធ្វើទ័ពដដែល ។

សេងគា៖ នៅភាមអណ្ដើកនឹង?

គូ ៖ ចាស៎!

សេងគា៖ គាត់នៅរហូតដល់បែក?

គូ ៖ ចាស៎! ដល់បែក ។

សេងគា៖ ហើយពេលទៅដល់នោះ អាហារហូបចុកយ៉ាងម៉េចដែរ ខុសពីមុន ឬក៏ដូចមុនទេ?

គូ ៖ ដូចគ្នាវាស់វែកឲ្យ គេវាស់វែកឲ្យយើងហូប ។

សេងគា៖ ម៉ាកំប៉ុងគ្នា២នាក់ដដែល?

គូ ៖ ចាស!

សេងគា៖ បាទ! មួយទៀតមីង ទាក់ទងពីរឿងការបំផ្លាញវត្តមិញ វត្តកំពែងមីងបានឮៗពីអ្នកណាគេមក?

គូ ៖ ចុះទៅឃើញ ។

សេងគា៖ មីងឮៗតាមរយៈអ្នកណាគេ តាមរយៈអ្នកណាគេចាស់ៗអ្នកណាគេខ្លះ?

គូ ៖ មានគេនិយាយប្រជាជនគ្រប់គ្នាគេនិយាយគ្រប់គ្នា ដល់ពេលទៅ ។

សេងគា៖ មីងអាចរាប់ឈ្មោះបានខ្លះ តើប្រជាជនអ្នកណាខ្លះៗដែលបាននិយាយ អ្នកនឹងឃើញផ្ទាល់ ឬក៏ឮគេតទៅទៀត?

គូ ៖ ឮគេនិយាយអីចឹង ដល់ពេលខ្ញុំទៅឃើញ ។

សេងគា៖ ឮតៗគ្នា ដល់ពេលទៅមើលវត្តនឹង ឃើញអីចឹង?

គូ ៖ ចាស!

សេងគា៖ ប៉ុន្តែមីងដឹងថានៅក្នុងនឹងមានប្រធានភូមិមួយឈ្មោះញៀបនឹង?

គូ ៖ ចាស! ប្រធានឃុំ ។

សេងគា៖ ប្រធានឃុំឈ្មោះញៀបនឹង គាត់ទទួលបញ្ជាពីគេមក គេឲ្យវ៉ៃចោលម៉ង?

គូ ៖ មិនដឹងគេ វ៉ៃម៉េច ដឹងតែ ។

សេងគា៖ តែដឹងថាកុដិនៅនឹងគេវ៉ៃចោលអីចឹង?

គូ ៖ ចាស!

សេងគា៖ កាលនឹងគេវ៉ៃនឹងមីងឮគេនិយាយវ៉ៃពេលយប់ ពេលថ្ងៃ ឬពេលណាទេ?

គូ ៖ មិនដឹងផង ។

សេងគា៖ ហើយដឹងអំឡុងឆ្នាំណា?

គូ ៖ ឆ្នាំ ។

សេងគា៖ បន្ទាប់ពីមីងការហើយ ឬក្រោយមីងការហើយ?

គូ ៖ មុនការ ។

សេងគា៖ មុនការទៀត?

គូ ៖ ចាស! ដល់ពេលខ្ញុំការហើយបានម៉ាឆ្នាំ គេរំដោះបាន ។

សេងគា៖ អីចឹងមីងការប៉ុន្មានឆ្នាំ?

គូ ៖ ម៉ាឆ្នាំ ។

សេធគា: អីចឹងឆ្នាំ៧៦ដែរ?

គូ :	ចា៎ស!

សេធគា: ពេលដែលគេវ៉ៃចោល គេយកអីមកវ៉ៃកាលនឹងមីងដឹង?

គូ :	មិនដឹង កាលទៅឃើញ ។

សេធគា: ឬក៏គេបាញ់កាំទេចម៉ង?

គូ :	មិនដឹងផង គ្រាន់ទៅឃើញ ។

សេធគា: មីងឮចាស់ៗនិយាយថាម៉េច?

គូ :	មិនឮផង គ្រាន់ថា ។

សេធគា: មីងដែលមានឮអ្នកណាឃើញផ្ទាល់មកប្រាប់មីងទេ?

គូ :	អត់ ។

សេធគា: អត់មានទេ?

គូ :	គ្រាន់គេថាវិហារវត្តកំពែងនេះថាគេវ៉ៃបែកអស់ហើយ ថាអីចឹង ។

សេធគា: គេវ៉ៃអស់ គេប្រាប់មីងនឹង រយៈពេលប៉ុន្មានបានមីងឃើញកន្លែងវិហារនឹងកំទេចចោល?

គូ :	យូរដែរ ទៅឃើញ ។

សេធគា: ប៉ុន្មានឆ្នាំ ឬបែកអាពតហើយ?

គូ :	អឺ!បែក៤-១០ថ្ងៃ យើងទៅដួសទឹក ទៅរែកទឹក ។

សេធគា: មីងឃើញគេវ៉ៃបាក់បែកនឹងមានឈាម មានអី ឬបាក់បែកធម្មតាទេ?

គូ :	វ៉ៃបែកធម្មតា ។

សេធគា: ចុះមីងដឹងថាមូលហេតុដែលគេវ៉ៃទេ?

គូ :	មិនដឹង ។

សេធគា: ចុះការវត្តនឹងរុះ មានដឹងថាមានលោកមានអីនៅក្នុងនឹង?

គូ :	លោកសឹកបាត់អស់ហើយ ។

សេធគា: លោកសឹកអស់ហើយ បានគេវ៉ៃ?

គូ :	កុដិនឹងបានគេថាគេរុះ ខ្ញុំចង់ទៅមើលតាខ្ញុំគាត់អ្នកកសាងកុដិនឹង ។

សេធគា: តាមីងឈ្មោះអី?

គូ :	តាខ្ញុំឈ្មោះ តានង អ្នកកសាងកុដិនឹង២ខ្នង ។

សេធគា: គេវ៉ៃចោលទាំងអស់?

គូ ៖ ដល់ពេលគេរុះចោល ទៅមើល ពុកគេនិយាយថារុះអីចឹង ដល់នេះខ្ញុំទៅមើលបានដឹង ។

សេងគា៖ ដល់នេះលោកចេញអស់ហើយ ចេញយូរហើយ?

គូ ៖ លោកចេញអស់ហើយ ។

សេងគា៖ លោកចេញបានប្រហែលប៉ុន្មានឆ្នាំ បានគេរើចោលអីចឹង?

គូ ៖ បែបម៉ាឆ្នាំ ។

សេងគា៖ វត្តនឹងទុកចោលអស់ហើយបានគេរើ?

គូ ៖ ចា៎ស!

សេងគា៖ អីចឹងអរគុណច្រើនមីង ចុងក្រោយមីងមានពាក្យពេចន៍អ៊ីចង់សួរឆ្លល់អី ចង់សួរខាងខ្ញុំវិញទេ?

គូ ៖ មិនដឹងសួរថាម៉េច គ្រាន់ថាប្អូនមកសួរនឹងសួរថា គ្រាន់ប្អូនសួរដឹងចង់ដឹងសួររឿងប្រវត្តិពីដើមមក មិនដឹងសួរថាម៉េចទៀត ។

សេងគា៖ មីងអត់មានសួរ ដូចបងបញ្ជាក់មិញអីចឹង ថាខាងខ្ញុំសុំបទសម្ភាសន៍របស់មីងយកទៅប្រើប្រាស់ដូចជាសរសេរអត្ថបទក្នុងទស្សនាវដ្ដី ហើយមួយទៀត ជារឿងរ៉ាវប្រវត្តិសាស្ត្រក្នុងការស្រាវ ជ្រាវជាឯកសារផ្សេងៗ ។ កាលដែលខ្ញុំសុំអីចឹង ខ្ញុំអនុញ្ញាតិមីងព្រមឲ្យធ្វើអីចឹងដែរ?

គូ ៖ ចុះខ្ញុំមានទំនាស់អី ខ្ញុំគ្មានរឿងអីទៅទំនាស់ ព្រោះសួរចង់ដឹងឲ្យកូនចៅទៅមុខទៅ ។

សេងគា៖ បាទ! ភាគច្រើនការដែលគោរព ត្រូវគោរពសិទ្ធិអ្នកដែលម្ចាស់ពត៌មានដូចច្នេះហើយខាងខ្ញុំនឹងបញ្ជាក់ម្ដងទៀត ខ្លាចមីងអត់ព្រមឲ្យ ខាងខ្ញុំអត់ហ៊ានធ្វើដែរ អីចឹងទាល់តែមីងព្រមអនុញ្ញាតិខាងខ្ញុំក៏សប្បាយចិត្តនឹងធ្វើ ។ ជាចុងក្រោយ ខ្ញុំអរគុណច្រើន ។

រ៉ាស៊ី ៖ មីងដែលបានស្ដាប់វ៉ាដ្យូ ពីរឿងតុលាការខ្មែរក្រហម?

គូ ៖ បានស្ដាប់ពុកដែរ ។

រ៉ាស៊ី ៖ មីងយល់ខ្លះៗពីតុលាការនឹង? មីងដែលស្ដាប់វិទ្យុអាស៊ីសេរី ឬកវិទ្យុសម្លេងសហរដ្ឋអាមេរិចមីងពីម៉ោង៨កន្លះដល់៩យប់ ថ្ងៃសៅរ៍ ថ្ងៃអាទិត្យមីងបើកទៅមានល្ខោននិយាយមួយៗគេនិយាយពីជីវិតរស់នៅក្នុងជំនាន់ប៉ុលពតនឹង ក្នុងនឹងមាន៧សាច់រឿង ។ ហើយសាច់រឿងនីមួយៗ រំលឹកឡើងវិញពីរបបរបស់គាត់ដែលធ្វើកន្លងមក មានតាំងពីរឿងចាប់រំលោភ មានតាំងពីរឿងធ្លាប់យកអ្នកភូមិយកទៅឲ្យធ្វើនេះធ្វើនោះ ដល់ក្រោយបែក៧៩មក អ្នកទាំង២នឹងជួបគ្នានិយាយរំលឹករឿងនឹងឡើង ។ មីងស្ដាប់ទៅរឿងនឹងគួរឲ្យចង់ស្ដាប់ ។

គូ ៖ វាអត់មានវ៉ាដ្យូផង មើលតែទូរទស្សន៍ ។

រ៉ាស៊ី ៖ មើលទូរទស្សន៍ដែរ?

គូ ៖ ដូចថាពេលលេងពីរឿងប៉ុលពតអីចឹង បើកមើលទូរទស្សន៍នឹងមាន ខ្ញុំអត់មានរ៉ាដ្យូ ។

រ៉ាស៊ី ៖ អត់មានរ៉ាដ្យូ?

គូ ៖ ចាស!

រ៉ាស៊ី ៖ ទូរស័ព្ទមានៗរ៉ាដ្យូ?

គូ ៖ ទិញអាចុចពិលនឹង ។

រ៉ាស៊ី ៖ Nចុចពិល?

គូ ៖ ចាស!

រ៉ាស៊ី ៖ មីងដែលបានទទួលសៀវភៅអីចឹង ពត៌មានផ្សេងៗទាក់ទងពីរឿង?

គូ ៖ អត់ដែរ ។

រ៉ាស៊ី ៖ អរគុណមីងច្រើន រំខានពេលវេលាមីងច្រើនបន្តិច ម៉ាម៉ោងជាងហើយ ។

គូ ៖ រំខានអី ខ្ញុំឈឺធ្វើអីមិនកើតផង ខ្សោយបេះដូង ។

រ៉ាស៊ី ៖ ខ្សោយបេះដូង?

គូ ៖ ចាស! និយាយអីគេនិយាយមកស្រែក និយាយអីរឿងភ័យស្លក់ ។

រ៉ាស៊ី ៖ ទើបតែឈឺឥឡូវ?

គូ ៖ ឈឺតាំងពីនៅក្មេង ម៉ែខ្ញុំគាត់ចិញ្ចឹមកូនមិនកប ហើយដល់ពេលគាត់សុំទៅ បងខ្ញុំគាត់ស្លាប់៥នាក់មុន ហើយដល់ពេលនឹងក៏មិនសូវជា ។

រ៉ាស៊ី ៖ ដល់ពេលខ្ញុំជួបមីងអីចឹង មីងអត់ភ័យអត់អីទេ?

គូ ៖ អត់អីទេ ទាល់មកសួរនេះអីចឹងមិនអី ដល់ពេលគេមកនិយាយប្រាប់ថាចេះៗ ឧទាហរណ៍ឲ្យយើងភ័យ ។

រ៉ាស៊ី ៖ កុំភ័យអីមីង អត់អីទេ?

គូ ៖ គេថាកូនទៅណាឆ្ងាយរកស៊ីចេះៗ ភ័យ អានឹងដូចចោលលួចគោថ្ងៃមុន កូនខ្ញុំអីចឹង ឆ្នាំមុនគេប្រាប់ចោលលួចគោ ស្លុងខ្លួនលែងដឹងអីនិយាយក៏មិនចេញ ។

រ៉ាស៊ី ៖ ខ្ញុំធ្លាប់មកជួបមីងម្នាក់ឈ្មោះមីងគា មីងស្គាល់ ឈ្មោះទៀក គា តាំងពីឆ្នាំ២០០៥ ២០០៦?

យាយ៖ នៅណា?

វ៉ាស៊ី ៖ នៅនេះ នៅហាន់ទា មីងគា អាយុប្រហែល៥០ គាត់នឹងមានប្រវត្តិរូប ខ្ញុំយកប្រវត្តិរូបយកមកឲ្យគាត់ ខ្ញុំប្រាប់គាត់ គាត់ភ្ញាក់ថាខ្ញុំធ្វើយូរហើយម៉េចក៏មានប្រវត្តិរូបនៅខ្ញុំវិញ មានសេសសល់ ។

គូ ៖ ចុះយើងធ្វើមែន ក៏គេដាក់ឲ្យយើងធ្វើ យើងមិន ខ្ញុំធ្វើក៏ខ្ញុំមិនដែលធ្វើបាបអីណា ដើរសួរចុះ ។ ដូចគេប្រមូលមាស តាមភូមិតាមអី ខ្ញុំវ៉ាន់មិនដែលដឹងអីទឹងគេ ដល់ពេលចុះមកអ្នកខូចឧទាហរណ៍ប្រមូលមាស ប្រមូលអីគេយក គេតាមទារយកវិញ ។ ខ្ញុំវ៉ាន់គ្មានដឹងអី ខ្ញុំមិនដែលទៅប្រមូលទៅអី ។

វ៉ាស៊ី ៖ អីចឹងអរគុណមីងច្រើន លោកយាយអរគុណច្រើន ដែលបានចំណាយពេលជាមួយខ្ញុំអស់ម៉ោងម៉ោងជាង ។

គូ ៖ ហើយមីងនិយាយខុសត្រូវអីប្អូនកុំប្រកាន់ ។

វ៉ាស៊ី ៖ បាទ! អត់អីទេមីង ។

«ចប់»